# ដំណឹងល្អរៀបរៀងដោយលោកយ៉ូហាន

## ពាក្យលំនាំ

លោកយ៉ូហានជា«សាវ័កដែលព្រះយេស៊ូស្រឡាញ់» ជាកូនរបស់លោកសេបេដេ និងជាប្អូនរបស់លោកយ៉ាកុប។ លោកបានរៀបរៀងកំណ្ឌគម្ពីរនេះក្នុងគ.ស.៩០-៩៥។

### គោលបំណងរបស់លោកយ៉ូហាន

លោកមានបំណងបកស្រាយអត្ថន័យដ៏លាក់កំបាំងអំពីកិច្ចការទាំងប៉ុន្មានដែលព្រះយេស៊ូបានធ្វើដើម្បីពង្រឹងជំនឿរបស់គ្រីស្តបរិស័ទ។ លោករ៉ាយរ៉ាប់តែព្រឹត្តិការណ៍ខ្លះដែលជាទីសម្គាល់បង្ហាញអំពីឋានៈរបស់ព្រះយេស៊ូជាព្រះគ្រីស្តនិងជាព្រះបុត្រារបស់ព្រះជាម្ចាស់។

### ពាក្យពេចន៍

លោកយ៉ូហានបានពន្យល់អត្ថន័យនៃជីវប្រវត្តិព្រះយេស៊ូដោយប្រើពាក្យពេចន៍ដកស្រង់ពីព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ និងទស្សនវិជ្ជាក្រិកជំនាន់នោះ។ ឧបមាថា:

ព្រះបន្ទូល *គឺព្រះយេស៊ូ។ ព្រះអង្គជាព្រះបុត្រារបស់ព្រះបិតា ទ្រង់បានបង្កើតអ្វីៗទាំងអស់ទ្រង់ជ្រាបព្រះតំរិះរបស់ព្រះបិតាសព្វគ្រប់ ហើយទ្រង់ប្រសូតមកជាមនុស្ស ដើម្បីបង្ហាញឲ្យមនុស្សយើងស្គាល់ព្រះបិតា។*

ព្រះនាម *សំដៅទៅលើប្ញទ្ធានុភាពនិងអំណាចរបស់ព្រះជាម្ចាស់។*

សិរីរុងរឿង *គឺព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតា។លោកយ៉ូហានមានបំណងពន្យល់ថាព្រះយេស៊ូបង្ហាញព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតាគ្រប់ពេលវេលាជាពិសេសនៅពេលព្រះអង្គសោយទិវង្គត។*

ពេលកំណត់ *ជាពេលដែលព្រះយេស៊ូសម្តែងសិរីរុងរឿង គឺពេលព្រះអង្គសោយទិវង្គតនៅលើឈើឆ្កាង។*

ជីវិតឬជីវិតអស់កល្បជានិច្ច *គឺព្រះជន្មរបស់ព្រះបិតាផ្ទាល់ដែលព្រះយេស៊ូប្រោសប្រទានឲ្យអស់អ្នកជឿសង្ឃឹមលើព្រះអង្គ។ លោកយ៉ូហានប្រើពាក្យ«ជីវិត» មានន័យប្រហាក់ប្រហែលនឹងពាក្យ«ព្រះរាជ្យ» ដែលលោកម៉ាថាយ លោកម៉ាកុស និង លោកលូកានិយមប្រើ។*

សេចក្តីពិតឬសេចក្តីពិតប្រាកដតែមួយ *គឺព្រះជាម្ចាស់ដែលមានព្រះជន្មដ៏ពេញលក្ខណៈ។ ព្រះយេស៊ូសម្តែងសេចក្តីពិតឲ្យមនុស្សលោកស្គាល់ គឺព្រះអង្គសម្តែងឲ្យស្គាល់ព្រះបិតា។ អ្នកជឿទទួលសេចក្តីទាំងប៉ុន្មានដែលព្រះយេស៊ូសម្តែងប្រាប់ ហើយចូលរួមជាមួយព្រះអង្គ។*

*រីឯហេតុទាំងប៉ុន្មានដែលបណ្តាលឲ្យមនុស្សឃ្លាតចាកពីព្រះជាម្ចាស់ លោកយ៉ូហានហៅថា សេចក្តីកុហក*

*ករឬសេចក្តីកុហក ។ ដូច្នេះ មារសាតាំងជាមេភូតករឬអ្នកសម្លាប់ព្រោះវានាំមនុស្សឲ្យឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ដែលជាប្រភពនៃជីវិត និងជាសេចក្តីពិត។*

បន្ទាល់ *គឺអ្នកផ្តល់សក្ខីភាពអំពីសេចក្តីពិតអ្នកស្គាល់ហេតុការណ៍ដែលកើតមានមកនិងពន្យល់អត្ថន័យផង។ព្រះបិតាព្រះវិញ្ញាណលោកយ៉ូហានបាទីស្តសាវ័កយ៉ូហានពួកសាវ័កនិងកិច្ចការទាំងប៉ុន្មានដែលព្រះយេស៊ូបានធ្វើសុទ្ធតែជាបន្ទាល់បញ្ជាក់អំពីឋានៈរបស់ព្រះយេស៊ូ។*

ពន្លឺ និង សេចក្តីងងឹត *ពន្លឺគឺព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់និងរបស់ព្រះគ្រីស្ត។ រីឯសេចក្តីងងឹតសំដៅទៅលើអំពើបាបឬចិត្តអាក្រក់ដែលបណ្តាលឲ្យមនុស្សវៀរចាកឆ្ងាយពីព្រះជាម្ចាស់ពុំអាចទទួលព្រះជន្មរបស់ព្រះអង្គ។*

ពិភពលោក មនុស្សលោក ឬលោក *ពាក្យនេះមានអត្ថន័យផ្សេងៗជួនកាលមានន័យថាមនុស្សដែលរស់នៅលើផែនដីនេះជួនកាលសំដៅទៅលើសេចក្តីអាក្រក់គ្រប់បែបយ៉ាងដែលមាននៅក្នុងចិត្តគំនិតមនុស្ស ជាពិសេសចិត្តរឹងរូសរបស់អ្នកដែលមិនព្រមទទួលស្គាល់ព្រះគ្រីស្ត។*

*ស្គាល់ មានន័យថាជឿផង ស្រឡាញ់ផង។*

«ដំណឹងល្អតែងដោយលោកយ៉ូហាន»ស្រួលអានតែមានអត្ថន័យជ្រៅជាងគេ។ត្រូវអានមួយៗជាច្រើនដងដោយរិះគិតពិចារណា ជាពិសេសត្រូវទូលអង្វរព្រះវិញ្ញាណ សូមទ្រង់បំភ្លឺចិត្តគំនិតឲ្យយល់។

«ព្រះវិញ្ញាណណែនាំអ្នករាល់គ្នាឲ្យស្គាល់សេចក្តីពិតគ្រប់ជំពូក»(១៦.១៣)។

## គំរោងគម្ពីរយ៉ូហាន

- *បុរេកថា(១. ១-១៨)។*
- *លោកយ៉ូហានបាទីស្ត និង សាវ័កដើមដំបូងបង្អស់របស់ព្រះយេស៊ូ(១.១៩- ៥១)។*
- *ព្រះយេស៊ូបំពេញព្រះបរមកិច្ចរបស់ព្រះអង្គក្នុងចំណោមប្រជាជន(២.១- ១២.៥០)។*
- *ព្រះយេស៊ូនៅក្រុងយេរូសាឡឹមនិងភូមិជុំវិញ(១៣.១- ១៩.៤២)។*
- *ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនិង បង្ហាញខ្លួនឲ្យពួកសាវ័កឃើញ(២០.១- ៣១)។*
- *អវសានកថាៈ ព្រះយេស៊ូមកជួបពួកសាវ័កនៅស្រុកកាលីឡេ(២១.១- ៣៥)។*

# ដំណឹងល្អរៀបរៀងដោយ

# លោកយ៉ូហាន

## បុរេកថា

១កាលពីដើមដំបូងបង្អស់ ព្រះបន្ទូលមានព្រះជន្ម
១គង់នៅ។ ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ ហើយ
ព្រះបន្ទូលជាព្រះជាម្ចាស់។ ២ព្រះបន្ទូលបែរទៅរក
ព្រះជាម្ចាស់ កាលពីដើមដំបូងបង្អស់។ ៣អ្វីៗសព្វ
សារពើសុទ្ធតែកើតឡើងដោយសារព្រះបន្ទូល គឺក្នុង
បណ្ដាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមក ក្រៅពី
ព្រះអង្គបង្កើតនោះឡើយ។ ៤ព្រះបន្ទូលជាប្រភពនៃ
ជីវិត ហើយជីវិតនោះជាពន្លឺបំភ្លឺមនុស្សលោក។ ៥ពន្លឺ
ភ្លឺក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតពុំបានទទួលពន្លឺ
ទេ។

៦ព្រះជាម្ចាស់បានចាត់បុរសម្នាក់ ឈ្មោះយ៉ូ
ហានឲ្យមក។ ៧លោកបានមកធ្វើជាបន្ទាល់ផ្ដល់សក្ខី
ភាពអំពីពន្លឺ ដើម្បីឲ្យមនុស្សទាំងអស់ជឿដោយសារ
លោក។ ៨លោកយ៉ូហានមិនមែនជាពន្លឺទេគឺលោក
គ្រាន់តែមកផ្ដល់សក្ខីភាពអំពីពន្លឺប៉ុណ្ណោះ។ ៩ព្រះ
បន្ទូលជាពន្លឺដ៏ពិតប្រាកដតែមួយ ដែលមកក្នុងពិភព
លោក ហើយបំភ្លឺមនុស្សគ្រប់ៗរូប។ ១០ព្រះបន្ទូល
បានគង់ក្នុងពិភពលោក ហើយពិភពលោកកើតឡើង
ដោយសារព្រះអង្គ ប៉ុន្តែពិភពលោក ពុំបានទទួល
ស្គាល់ព្រះអង្គទេ។ ១១ព្រះបន្ទូលបានយាងមក គង់
ជាមួយប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ តែប្រជារាស្ត្រ
នោះពុំបានទទួលព្រះអង្គឡើយ។ ១២រីឯអស់អ្នក
ដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿលើព្រះ
នាមព្រះអង្គ ព្រះអង្គប្រទានឲ្យគេអាចទៅជាបុត្រ
ធីតារបស់ព្រះជាម្ចាស់។ ១៣អ្នកទាំងនោះពុំមែនកើត
ពីលោហិត ពីចំណង់តណ្ហា ឬពីការប៉ងប្រាថ្នារបស់
មនុស្សឡើយ គឺកើតពីព្រះជាម្ចាស់វិញ។

១៤ព្រះបន្ទូលបានកើតមកជាមនុស្ស ហើយគង់
នៅក្នុងចំណោមយើងរាល់គ្នា យើងបានឃើញសិរីរុង
រឿងរបស់ព្រះអង្គ ជាសិរីរុងរឿងនៃព្រះបុត្រាតែមួយ
គត់ ដែលមកពីព្រះបិតា ព្រះអង្គពោរពេញទៅដោយ
ព្រះហឫទ័យប្រណីសន្ដោស និងសេចក្ដីពិត។ ១៥
លោកយ៉ូហានបានផ្ដល់សក្ខីភាព អំពីព្រះអង្គ ដោយ
ប្រកាសថា៖ «គឺលោកនេះហើយ ដែលខ្ញុំនិយាយថា
"អ្នកមកក្រោយខ្ញុំ ប្រសើរជាងខ្ញុំ ដ្បិតលោកមាន
ជីវិតមុនខ្ញុំ"»។ ១៦យើងទាំងអស់គ្នាបានទទួលព្រះ
ហឫទ័យប្រណីសន្ដោស មិនចេះអស់មិនចេះហើយ
ពីគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ ១៧ដ្បិតព្រះជា
ម្ចាស់ប្រទានធម្មវិន័យ* តាមរយៈលោកម៉ូសេ ហើយ
ទ្រង់បានសម្ដែងព្រះហឫទ័យប្រណីសន្ដោស និងសេ
ចក្ដីពិត តាមរយៈព្រះយេស៊ូគ្រីស្ដ។ ១៨ពុំដែលមាន
នរណាម្នាក់ បានឃើញព្រះជាម្ចាស់ឡើយ មានតែ
ព្រះបុត្រាមួយព្រះអង្គប៉ុណ្ណោះ ដែលបាននាំយើងឲ្យ
ស្គាល់ព្រះអង្គ ដ្បិតព្រះបុត្រាមានព្រះជន្មរួមជាមួយ
ព្រះបិតា។

## សក្ខីភាពរបស់លោកយ៉ូហានបាទីស្ដ

(ម៉ាថាយ ៣. ១–១២ ម៉ាកុស ១. ១–៨ លូកា ៣. ១–១៨)

១៩ជនជាតិយូដាចាត់ពួកបូជាចារ្យ* និងពួកលេ
វី*ពីក្រុងយេរូសាឡឹម ឲ្យទៅជួបលោកយ៉ូហាន
ដើម្បីសួរថា៖ «លោកជានរណា?»។ ២០លោកយ៉ូ
ហានប្រកាសប្រាប់គេ ដោយពុំលាក់លៀមអ្វីឡើយ
គឺលោកបានបញ្ជាក់យ៉ាងច្បាស់ថា៖ «ខ្ញុំមិនមែនជា
ព្រះគ្រីស្ដ*ទេ»។ ២១ពួកគេសួរលោកថា៖ «ដូច្នេះតើ
លោកជានរណា? តើលោកជាព្យាការីអេលីឬ?»។
លោកឆ្លើយថា៖ «ទេ មិនមែនទេ !»។ គេក៏សួរ

ទៀតថា៖ «តើលោកជាព្យាការី* ដែលយើងរង់ចាំ
នោះឬ?»។ លោកឆ្លើយថា៖ «មិនមែនទេ!»។ ២២
គេសួរលោកទៀតថា៖ «តើលោកជានរណា? ដ្បិត
យើងខ្ញុំចង់បានចម្លើយ យកទៅជម្រាបអស់លោក
ដែលចាត់យើងខ្ញុំឲ្យមក តើលោកថា ខ្លួនលោកជា
នរណា!»។ ២៣លោកយ៉ូហានមានប្រសាសន៍ថា៖

*«ខ្ញុំជាសំឡេងបុរសម្នាក់ដែលស្រែក*
*នៅវាលរហោស្ថាន* ថា៖*
*"ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់"*

ត្រូវនឹងសេចក្តី ដែលព្យាការីអេសាយបានថ្លែង
ទុកមក»។ ២៤អ្នកដែលគេចាត់ឲ្យមកនោះជាពួក
ខាងគណៈផារីស៊ី*។ ២៥គេសួរលោកយ៉ូហានទៀត
ថា៖ «បើលោកមិនមែនជាព្រះគ្រិស្ត មិនមែនជាព្យា
ការីអេលី ហើយក៏មិនមែនជាព្យាការី ដែលយើងរង់
ចាំនោះទេ ហេតុដូចម្តេចបានជាលោកធ្វើពិធីជ្រមុជ
ទឹក*ដូច្នេះ?»។ ២៦លោកយ៉ូហានឆ្លើយទៅគេថា៖
«ខ្ញុំធ្វើពិធីជ្រមុជក្នុងទឹកមែន ប៉ុន្តែក្នុងចំណោមអ្នក
រាល់គ្នា មានម្នាក់ដែលអ្នករាល់គ្នាពុំស្គាល់ ២៧លោក
មកក្រោយខ្ញុំ លោកមានឋានៈខ្ពង់ខ្ពស់ណាស់ សូម្បី
តែឲ្យខ្ញុំស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសម
នឹងឋានៈរបស់លោកផង»។ ២៨ហេតុការណ៍នេះ
កើតមាននៅភូមិបេតថានី ខាងនាយទន្លេយ័រដាន់
ត្រង់កន្លែងលោកយ៉ូហានធ្វើពិធីជ្រមុជទឹក*។

## ព្រះយេស៊ូជាកូនចៀមរបស់ព្រះជាម្ចាស់

២៩នៅថ្ងៃបន្ទាប់ លោកយ៉ូហានឃើញព្រះ
យេស៊ូយាងតម្រង់មករកលោក លោកក៏មាន
ប្រសាសន៍ថា៖ «មើលហ្ន៎! លោកនេះហើយជាកូន
ចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបចេញពីមនុស្ស
លោក៣០គឺលោកនេះហើយ ដែលខ្ញុំបានប្រាប់អ្នក
រាល់គ្នាថា "អ្នកដែលមកក្រោយខ្ញុំប្រសើរជាងខ្ញុំ ដ្បិត
លោកមានជីវិតមុនខ្ញុំ"។ ៣១កាលពីដើមខ្ញុំពុំស្គាល់ឋា
នៈរបស់លោកទេ ប៉ុន្តែខ្ញុំមកធ្វើពិធីជ្រមុជក្នុងទឹក*
ដើម្បីឲ្យលោកបង្ហាញខ្លួនឲ្យប្រជារាស្ត្រអ៊ីស្រាអែល
ស្គាល់»។

៣២លោកយ៉ូហានបានផ្តល់សក្ខីភាពថា៖ «ខ្ញុំ
បានឃើញព្រះវិញ្ញាណ យាងចុះពីស្ថានបរមសុខ*
ដូចសត្វព្រាបមកសណ្ឋិតលើលោក។ ៣៣ពីមុនខ្ញុំពុំ
ស្គាល់ឋានៈលោកទេ ប៉ុន្តែព្រះជាម្ចាស់ដែលបានចាត់
ខ្ញុំឲ្យមកធ្វើពិធីជ្រមុជក្នុងទឹក ទ្រង់មានព្រះបន្ទូលមក
ខ្ញុំថា "អ្នកឃើញព្រះវិញ្ញាណយាងចុះមកសណ្ឋិតលើ
អ្នកណា គឺអ្នកនោះហើយ ដែលធ្វើពិធីជ្រមុជក្នុងព្រះ
វិញ្ញាណដ៏វិសុទ្ធ*"។ ៣៤ខ្ញុំបានឃើញដូច្នោះមែន
ហើយខ្ញុំសូមបញ្ជាក់ថា លោកនេះពិតជាព្រះបុត្រា
របស់ព្រះជាម្ចាស់មែន»។

## សាវ័កដែលតាមព្រះយេស៊ូមុនគេ

៣៥ថ្ងៃបន្ទាប់មកទៀត លោកយ៉ូហាននៅទីនោះ
ដដែល ហើយមានសិស្សរបស់លោកពីរនាក់នៅ
ជាមួយផង។ ៣៦លោកសំឡឹងមើលព្រះយេស៊ូយាង
កាត់តាមនោះក៏មានប្រសាសន៍ថា៖ «មើលហ្ន៎!
លោកនេះហើយ ជាកូនចៀមរបស់ព្រះជាម្ចាស់»។
៣៧កាលសិស្សទាំងពីរបានឮពាក្យនេះ គេនាំគ្នាដើរ
តាមព្រះយេស៊ូទៅ។ ៣៨ព្រះយេស៊ូងាកមកក្រោយ
ទតឃើញអ្នកទាំងពីរដើរតាម ព្រះអង្គក៏មានព្រះ
បន្ទូលសួរថា៖ «អ្នកទាំងពីរមករកអ្វី?»។ គេទូល
ព្រះអង្គថា៖ «រ៉ាប៊ី! (ពាក្យ "រ៉ាប៊ី" នេះប្រែថា "
លោកគ្រូ") តើលោកនៅកន្លែងណា?»។ ៣៩ព្រះអង្គ
មានព្រះបន្ទូលទៅគេវិញថា៖ «សុំអញ្ជើញមក អ្នក
នឹងបានឃើញ!»។ គេក៏ទៅឃើញកន្លែងដែលព្រះ
អង្គគង់នៅ ហើយគេក៏នៅជាមួយព្រះអង្គ នៅថ្ងៃនោះ
(ពេលនោះប្រហែលជាម៉ោងបួនរសៀល)។ ៤០ក្នុង
ចំណោមសិស្សទាំងពីរ ដែលបានឮពាក្យរបស់លោក
យ៉ូហាន ហើយតាមព្រះយេស៊ូទៅនោះ មានម្នាក់

ឈ្មោះអន់ទ្រេ ជាប្អូនរបស់លោកស៊ីម៉ូនសិលា*។៤១
គាត់ទៅជួបលោកស៊ីម៉ូនជាបង មុនគេប្រាប់ថា៖ «
យើងបានរកព្រះមែស្ស៊ីឃើញហើយ!» (ពាក្យ"មែ
ស្ស៊ី" នេះប្រែថា "ព្រះគ្រីស្ត")។ ៤២គាត់ក៏នាំលោក
ស៊ីម៉ូនទៅគាល់ព្រះយេស៊ូ។ ព្រះយេស៊ូសំឡឹងមើល
លោកស៊ីម៉ូន ក៏មានព្រះបន្ទូលថា៖ «អ្នកឈ្មោះស៊ីម៉ូ
ន ជាកូនរបស់លោកយ៉ូហាន អំណើះតទៅអ្នកត្រូវ
មានឈ្មោះថា "កេផាស" (ពាក្យ "កេផាស" នេះ
ប្រែថាសិលា*)។

៤៣លុះថ្ងៃបន្ទាប់មកទៀត ព្រះយេស៊ូសព្វព្រះហ
ឫទ័យយាងទៅស្រុកកាលីឡេ។ ព្រះអង្គបានជួប
លោកភីលីព ហើយមានព្រះបន្ទូលទៅគាត់ថា៖«
សូមអញ្ជើញមកតាមខ្ញុំ»។ ៤៤លោកភីលីពជាអ្នកភូមិ
បេតសៃដា ដូចលោកអន់ទ្រេ និងលោកសិលាដែរ។
៤៥លោកភីលីពទៅជួបលោកណាថាណាអែលប្រាប់
គាត់ថា៖ «លោកដែលធម្មវិន័យរបស់លោកម៉ូសេ
និងគម្ពីរព្យាការីចែងទុកនោះ ឥឡូវនេះយើងបាន
ឃើញហើយ លោកឈ្មោះយេស៊ូជាអ្នកភូមិណាសា
រ៉ែត ជាបុត្ររបស់លោកយ៉ូសែប»។ ៤៦លោកណាថា
ណាអែលពោល តបទៅលោកភីលីពវិញថា៖ «ពុំ
ដែលមានអ្វីល្អអាចចេញពីភូមិណាសារ៉ែតបាន
ឡើយ»។ ៤៧លោកភីលីពប្រាប់គាត់ថា៖ «សូម
អញ្ជើញមកអ្នកនឹងបានឃើញ!»។កាលព្រះយេស៊ូ
ទត ឃើញលោកណាថាណាអែលដើរមករកព្រះអង្គ
ព្រះអង្គមានព្រះបន្ទូលអំពីគាត់ថា៖ «អ្នកនេះជាជាតិ
អ៊ីស្រាអែលដ៏ពិតប្រាកដមែន ដ្បិតគាត់គ្មានពុតត្បុត
អ្វីក្នុងខ្លួនសោះ»។ ៤៨លោកណាថាណាអែលទូល
សួរព្រះអង្គថា៖ «តើលោកគ្រូដែលស្គាល់ខ្ញុំពី
អង្កាល់?»។ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖«ខ្ញុំ
បានឃើញអ្នក កាលអ្នកនៅក្រោមដើមឧទុម្ពរ មុនភី
លីពហៅអ្នកទៅទៀត»។ ៤៩លោកណាថាណាអែល
ទូលព្រះអង្គថា៖ «ព្រះគ្រូ! ព្រះអង្គពិតជាព្រះបុត្រា
របស់ព្រះជាម្ចាស់ ហើយពិតជាព្រះមហាក្សត្ររបស់
ជនជាតិអ៊ីស្រាអែលមែន»។ ៥០ព្រះយេស៊ូមានព្រះ
បន្ទូលទៅគាត់ថា៖ «អ្នកបានជឿមកពីឮខ្ញុំនិយាយ
ថា ខ្ញុំបានឃើញអ្នកនៅក្រោមដើមឧទុម្ពរ* "ថ្ងៃ
ក្រោយអ្នកមុខតែឃើញការអស្ចារ្យលើសនេះទៅ
ទៀត»។ ៥១ព្រះអង្គមានព្រះបន្ទូលថែមទៀតថា៖ «
ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នករាល់គ្នានឹង
ឃើញផ្ទៃមេឃបើកចំហ ហើយមានពួកទេវទូត*
របស់ព្រះជាម្ចាស់ ចុះឡើងពីលើបុត្រមនុស្ស*»។

## ពិធីមង្គលការនៅភូមិកាណា

១បីថ្ងៃក្រោយមក មានគេរៀបពិធីមង្គលការ នៅ
២ភូមិកាណា ក្នុងស្រុកកាលីឡេ។ មាតាព្រះយេស៊ូ
នៅទីនោះ ២ហើយគេក៏បានយាងព្រះយេស៊ូ និង
អញ្ជើញពួកសាវ័ក*របស់ព្រះអង្គទៅចូលរួមក្នុងពិធី
មង្គលការនោះដែរ។ ៣ពេលនោះគេខ្វះស្រាទំពាំង
បាយជូរ។ មាតាព្រះយេស៊ូទូលព្រះអង្គថា៖ «គេអស់
ស្រាទំពាំងបាយជូរហើយ!»។ ៤ព្រះយេស៊ូមានព្រះ
បន្ទូលទៅមាតាថា៖ «អ្នកម្ដាយអើយ! កុំរវល់នឹង
រឿងនេះអី ពេលកំណត់របស់ខ្ញុំ ពុំទាន់មកដល់នៅ
ឡើយទេ»។ ៥មាតារបស់ព្រះអង្គប្រាប់ទៅពួកអ្នក
បម្រើ ថា៖ «បើលោកប្រាប់ឲ្យធ្វើអ្វី ចូរធ្វើតាមទៅ»
។ ៦នៅទីនោះមានពាងប្រាំមួយ ដែលជនជាតិយូដា
ដាក់ទឹក សម្រាប់ធ្វើពិធីជំរះកាយ។ ពាងនីមួយៗមាន
ចំណុះប្រមាណជាពីរបីអំរែក។ ៧ព្រះយេស៊ូមានព្រះ
បន្ទូលទៅអ្នកបម្រើថា៖ «សុំដងទឹកមកចាក់ឲ្យពេញ
ពាងទាំងនេះទៅ»។ គេក៏ដងទឹកចាក់ពេញពាង។ ៨
ព្រះអង្គមានព្រះបន្ទូលថា៖ «ឥឡូវនេះសុំដងយក
ទៅជូនលោកចៅមហាទៅ» គេក៏ដងយកទៅជូន។
៩លោកចៅមហាភ្លក់ទឹកដែលបានប្រែមកជាស្រា
ទំពាំងបាយជូរ។ គាត់មិនដឹងថាគេបានស្រានេះមកពី
ណាឡើយ មានតែពួកអ្នកបម្រើដែលបានដងទឹកមក

ចាក់ពាង ទើបដឹង។ ១០គាត់ហៅកូនកំលោះមក
និយាយថា៖ «អ្នកផងទាំងពួងតែងយកស្រាទំពាំង
បាយជូរឆ្ងាញ់ មកជូនភ្ញៀវជាមុន លុះភ្ញៀវពិសាច្រើន
ហើយ ទើបគេយកស្រាមិនសូវឆ្ងាញ់មកជូនតាមក្រោ
យ។ រីឯអ្នកវិញ ម្ដេចក៏ទុកស្រាឆ្ងាញ់មកទល់ឥឡូវ
ដូច្នេះ!»។
១១នេះជាទីសម្គាល់ដំបូងបង្អស់ ដែលព្រះ
យេស៊ូបានធ្វើនៅភូមិកាណា ក្នុងស្រុកកាលីឡេ។
ព្រះអង្គបានសម្តែងសិរីរុងរឿង របស់ព្រះអង្គ ហើយ
ពួកសាវ័កក៏បានជឿលើព្រះអង្គ។ ១២បន្ទាប់មកព្រះ
អង្គយាងចុះទៅក្រុងកាផានុមជាមួយមាតា ព្រមទាំង
បងប្អូននិងសាវ័ករបស់ព្រះអង្គ ហើយស្នាក់នៅទី
នោះមួយរយៈពេលខ្លី។

## ព្រះយេស៊ូបណ្ដេញអ្នកលក់ដូរចេញពីព្រះវិហារ

(មថ ២១.១២-១៣ មក ១១.១៥-១៧ លក ១៩.៤៥-៤៦)

១៣បុណ្យចម្លង*របស់ជនជាតិយូដា ជិតមក
ដល់ហើយ ព្រះយេស៊ូក៏យាងឡើងទៅក្រុងយេរូសា
ឡឹម។ ១៤នៅក្នុងបរិវេណព្រះវិហារ*ព្រះអង្គឃើញ
អ្នកលក់គោ លក់ចៀម លក់ព្រាប និងអ្នកអង្គុយដូរ
ប្រាក់។ ១៥ព្រះអង្គយកខ្សែធ្វើរំពាត់ដេញអ្នកទាំង
នោះ ព្រមទាំងចៀមនិងគោរបស់គេចេញពីបរិវេណ
ព្រះវិហារ* ព្រះអង្គបាចប្រាក់អ្នកដូរប្រាក់ចោល
ហើយផ្កាប់តុរបស់គេផង។ ១៦ព្រះអង្គមានព្រះបន្ទូល
ទៅអ្នកលក់ព្រាបថា៖ «ចូរយករបស់ទាំងអស់នេះ
ចេញទៅ កុំយកដំណាក់ព្រះបិតាខ្ញុំធ្វើជាកន្លែងលក់
ដូរដូច្នេះឡើយ»។ ១៧ពួកសាវ័ក*នឹកឃើញសេចក្ដី
ដែលមានចែងទុកក្នុងគម្ពីរថា៖

*«មកពីទូលបង្គំស្រឡាញ់ព្រះដំណាក់របស់ព្រះ
អង្គបានជាគេប្រហារជីវិតទូលបង្គំ»។*

១៨ពេលនោះ ជនជាតិយូដាទូលសួរព្រះអង្គថា៖
«តើលោកមានទីសម្គាល់អ្វី បង្ហាញឲ្យយើងដឹងថា
លោកមានសិទ្ធិធ្វើការទាំងនេះ?»។ ១៩ព្រះយេស៊ូ
មានព្រះបន្ទូលឆ្លើយទៅគេថា៖ «ចូររុះព្រះវិហារ*
នេះចោលទៅ ខ្ញុំនឹងសង់ឡើងវិញក្នុងរវាងបីថ្ងៃ»។២០
ជនជាតិយូដាតបថា៖ «គេបានចំណាយពេល
សែសិបប្រាំមួយឆ្នាំ ដើម្បីសង់ព្រះវិហារនេះ រីឯលោក
លោកនឹងសង់ឡើងវិញក្នុងរវាងតែបីថ្ងៃប៉ុណ្ណោះឬ?»
។ ២១តាមពិតព្រះយេស៊ូមានព្រះ បន្ទូលសំដៅទៅ
លើព្រះវិហារ ដែលជារូបកាយរបស់ព្រះអង្គវិញឯ
ណោះទេ។ ២២ពេលព្រះអង្គមានព្រះជន្មរស់ឡើងវិញ
ពួកសាវ័កនឹកឃើញថា ព្រះអង្គមានព្រះបន្ទូលដូច្នេះ
គេក៏ជឿព្រះគម្ពីរ ព្រមទាំងជឿព្រះបន្ទូលរបស់ព្រះ
យេស៊ូដែរ។

## ព្រះយេស៊ូយល់ជំរៅចិត្តមនុស្ស

២៣ពេលព្រះយេស៊ូគង់ នៅក្រុងយេរូសាឡឹម
ក្នុងឱកាសបុណ្យចម្លង* មានមនុស្សជាច្រើនបាន
ជឿលើព្រះនាមព្រះអង្គ ដោយឃើញទីសម្គាល់ដែល
ព្រះអង្គបានធ្វើ។ ២៤ប៉ុន្តែព្រះយេស៊ូពុំទុកចិត្តគេទេ
ដ្បិតព្រះអង្គស្គាល់ចិត្តគំនិតអ្នកទាំងនោះ ២៥មិនបាច់
មាននរណាពន្យល់ព្រះអង្គ អំពីចិត្តមនុស្សឡើយ
ព្រោះព្រះអង្គឈ្វេងយល់អ្វីៗទាំងអស់ នៅក្នុងចិត្ត
មនុស្ស។

## ព្រះយេស៊ូសន្ទនាជាមួយលោកនីកូដេម

១មាននាម៉ឺនជាតិយូដាម្នាក់ ឈ្មោះ នីកូដេម លោក
៣នៅខាងគណៈផារីស៊ី*។ ២លោកបានមកគាល់
ព្រះយេស៊ូទាំងយប់ ហើយទូលថា៖ «លោកគ្រូ
យើងខ្ញុំដឹងថា ព្រះជាម្ចាស់បានចាត់លោកគ្រូឲ្យមក
បង្រៀនយើងខ្ញុំ ដ្បិតគ្មាននរណាអាចធ្វើទីសម្គាល់
ដូចលោកគ្រូបានឡើយ វៀរលែងតែ ព្រះជាម្ចាស់គង់
ជាមួយអ្នកនោះ»។ ៣ព្រះយេស៊ូមានព្រះបន្ទូលទៅ
គាត់ថា៖ «ខ្ញុំសូមជម្រាបលោកឲ្យដឹងច្បាស់ថា

ប្រសិនបើមនុស្សមិនកើតជាថ្មីទេ គេមិនអាចឃើញ
ព្រះរាជ្យ* របស់ព្រះជាម្ចាស់បានឡើយ»។ ៤លោក
នីកូដេមទូលសួរព្រះអង្គថា៖ «ចុះបើមនុស្សមានវ័យ
ចាស់ទៅហើយ ធ្វើដូចម្ដេចអាចកើតម្ដងទៀតបាន?
តើគេអាចចូលទៅក្នុងផ្ទៃម្ដាយ ហើយកើតម្ដងទៀត
បានឬ?»។ ៥ព្រះយេស៊ូមានព្រះបន្ទូលតបថា៖«ខ្ញុំ
សូមជម្រាបលោកឲ្យដឹងច្បាស់ថា ប្រសិនបើមនុស្ស
មិនកើតពីទឹកនិងពីព្រះវិញ្ញាណទេ គេពុំអាចចូលក្នុង
ព្រះរាជ្យព្រះជាម្ចាស់បានឡើយ។ ៦អ្នកណាកើតមក
ជាមនុស្ស អ្នកនោះនៅតែជាមនុស្សដដែល រីឯអ្នក
ដែលកើតពីព្រះវិញ្ញាណវិញ មានព្រះវិញ្ញាណក្នុងខ្លួ
ន។ ៧ពេលខ្ញុំជម្រាបលោកថា "អ្នករាល់គ្នាត្រូវកើត
ជាថ្មី" សូមកុំឆ្ងល់ឲ្យសោះ។ ៨ខ្យល់ចង់បក់ទៅទិស
ណាក៏បានលោកឮស្នូរវា តែលោកពុំដឹងថា ខ្យល់បក់
មកពីទីណាទៅទីណាឡើយ រីឯអ្នកដែលកើតមកពី
ព្រះវិញ្ញាណ ក៏ដូច្នោះដែរ»។ ៩លោកនីកូដេមទូល
សួរព្រះអង្គថា៖ «តើការទាំងនេះអាចនឹងកើតឡើង
ដូចម្ដេចបាន?»។ ១០ព្រះយេស៊ូមានព្រះបន្ទូលថា៖
«លោកជាគ្រូរបស់ជនជាតិអ៊ីស្រាអែល ម្ដេចក៏លោក
មិនជ្រាបសេចក្ដីទាំងនេះ? ១១ខ្ញុំសូមជម្រាបលោកឲ្យ
ដឹងច្បាស់ថា យើងនិយាយអំពីសេចក្ដីណាដែល
យើងដឹងហើយ យើងធ្វើជាបន្ទាល់បញ្ជាក់នូវហេតុ
ការណ៍ណា ដែលយើងបានឃើញតែអ្នករាល់គ្នា មិន
ទទួលសក្ខីភាពរបស់យើងទេ។ ១២ពេលខ្ញុំនិយាយ
អំពីហេតុការណ៍ នៅលើផែនដីអ្នករាល់គ្នាមិនជឿទៅ
ហើយ ចុះទំរាំបើខ្ញុំនិយាយអំពីហេតុការណ៍ នៅស្ថាន
បរមសុខវិញ តើអ្នករាល់គ្នានឹងជឿដូចម្ដេចបាន!។
១៣ពុំដែលមាននរណាបានឡើងទៅស្ថានបរមសុខ
ឡើយ គឺមានតែបុត្រមនុស្ស*ប៉ុណ្ណោះ ដែលបាន
យាងចុះពីស្ថានបរមសុខមក។

១៤កាលនៅវាលរហោស្ថាន លោកម៉ូសេបាន
លើកពស់ឡើងយ៉ាងណា បុត្រមនុស្សនឹងត្រូវគេ
លើកឡើងយ៉ាងនោះដែរ ១៥ដើម្បីឲ្យអស់អ្នកដែល
ជឿលើព្រះអង្គមានជីវិតអស់កល្បជានិច្ច។ ១៦ព្រះជា
ម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះ
ហើយ បានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់
ព្រះអង្គមក ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះបុត្រា
មានជីវិតអស់កល្បជានិច្ចគឺមិនឲ្យគេវិនាសឡើយ។
១៧ព្រះជាម្ចាស់បានចាត់ព្រះបុត្រារបស់ព្រះអង្គ ឲ្យ
យាងមកក្នុងលោកនេះពុំមែនដើម្បីដាក់ទោសមនុស្ស
លោកទេ គឺដើម្បីសង្គ្រោះមនុស្សលោកដោយសារ
ព្រះបុត្រាវិញ។ ១៨អ្នកជឿលើព្រះបុត្រាមិនត្រូវទទួល
ទោសទេ រីឯអ្នកមិនជឿបានទទួលទោសរួចស្រេច
ទៅហើយ ព្រោះគេពុំបានជឿលើព្រះនាមព្រះបុត្រា
តែមួយ របស់ព្រះជាម្ចាស់។ ១៩ហេតុដែលបណ្ដាល
ឲ្យមានទោសនោះ គឺពន្លឺបានយាងមកក្នុងពិភព
លោក ប៉ុន្តែមនុស្សលោកចូលចិត្តភាពងងឹតជាងពន្លឺ
ដ្បិតអំពើរបស់គេសុទ្ធតែអាក្រក់។ ២០អស់អ្នកដែល
ប្រព្រឹត្តអំពើអាក្រក់តែងតែស្អប់ពន្លឺ ហើយមិនចូល
មករកពន្លឺឡើយ ព្រោះខ្លាចគេឃើញអំពើដែលខ្លួន
ប្រព្រឹត្ត។ ២១ផ្ទុយទៅវិញអស់អ្នកដែលប្រព្រឹត្តតាម
សេចក្ដីពិត តែងតែចូលមករកពន្លឺ ដើម្បីឲ្យគេឃើញ
ថា អំពើដែលខ្លួនប្រព្រឹត្តនោះស្របតាមព្រះជាម្ចាស់
មែន»។

## សក្ខីភាពរបស់លោកយ៉ូហានបាទីស្ដ

២២បន្ទាប់មក ព្រះយេស៊ូយាងទៅស្រុកយូដា
ជាមួយពួកសាវ័ក*។ ព្រះអង្គស្នាក់នៅទីនោះជាមួយ
គេព្រមទាំងជ្រមុជទឹក* ឲ្យបណ្ដាជនផង។ ២៣រីឯ
លោកយ៉ូហានវិញ លោកក៏ជ្រមុជទឹកឲ្យគេនៅអេណូ
ន ក្បែរភូមិសាលីមដែរ ព្រោះនៅទីនោះមានទឹកច្រើ
ន។ មនុស្សម្នានាំគ្នាមករកលោក ហើយលោកជ្រមុជ
ទឹកឲ្យ។ ២៤កាលណោះលោកយ៉ូហានមិនទាន់ជាប់
ឃុំឃាំងនៅឡើយទេ។

២៥ពេលនោះ ពួកសិស្សរបស់លោកយ៉ូហាន
និងជនជាតិយូដាម្នាក់ជជែកគ្នា អំពីពិធីជម្រះកាយឲ្យ
បានបរិសុទ្ធ*។ ២៦គេនាំគ្នាទៅជួបលោកយ៉ូហាន
ជម្រាបថា៖ «លោកគ្រូ! បុរសដែលនៅជាមួយ
លោកខាងនាយទន្លេយ័រដាន់ ពីថ្ងៃមុន ហើយដែល
លោកផ្ដល់សក្ខីភាពឲ្យនោះ ឥឡូវនេះគាត់កំពុងតែ
ជ្រមុជទឹក*ឲ្យគេ មនុស្សទាំងអស់នាំគ្នាទៅរកគាត់»
។ ២៧លោកយ៉ូហានមានប្រសាសន៍តបទៅគេថា៖ «
បើព្រះជាម្ចាស់មិនប្រទានឲ្យទេ គ្មាននរណាម្នាក់អាច
ធ្វើអ្វីកើតឡើយ។ ២៨អ្នករាល់គ្នាជាបន្ទាល់ស្រាប់
ហើយខ្ញុំបាននិយាយថា ខ្ញុំមិនមែនជាព្រះគ្រិស្តទេ គឺ
ព្រះជាម្ចាស់បានចាត់ខ្ញុំឲ្យមកមុនព្រះអង្គ។ ២៩នៅ
ក្នុងពិធីមង្គលការ កូនក្រមុំរៀបការនឹងអ្នកណា អ្នក
នោះហើយជាស្វាមី។ រីឯមិត្តសំឡាញ់របស់ស្វាមី គេ
ឈរស្ដាប់នៅក្បែរគាត់ និងមានចិត្តត្រេកអរក្រៃលែង
ដោយបានឮសំឡេងរបស់គាត់។ ខ្ញុំក៏ពោរពេញ
ដោយអំណរដូច្នោះដែរ។ ៣០ព្រះអង្គត្រូវតែចម្រើន
ឡើង រីឯខ្ញុំវិញ ខ្ញុំត្រូវតែអន់ថយ។ ៣១ព្រះអង្គដែល
យាងពីស្ថានបរមសុខមក ទ្រង់មានឋានៈធំលើសគេ
ទាំងអស់។ អ្នកដែលកើតពីលោកីយ៍នៅតែជា
លោកីយ៍ដដែល ហើយនិយាយតែពីរឿងលោកីយ៍។
ព្រះអង្គដែលយាងពីស្ថានបរមសុខមក ទ្រង់មានឋា
នៈធំលើសគេទាំងអស់។ ៣២ព្រះអង្គធ្វើជាបន្ទាល់
បញ្ជាក់ពីអ្វីៗទាំងអស់ ដែលទ្រង់បានឃើញនិងបាន
ឮ ប៉ុន្តែគ្មាននរណាទទួលសក្ខីភាពរបស់ព្រះអង្គទេ។
៣៣អ្នកដែលទទួលសក្ខីភាពរបស់ព្រះអង្គ បាន
បញ្ជាក់ថា ព្រះជាម្ចាស់បានសម្តែងសេចក្តីពិតមែន។
៣៤ព្រះអង្គដែលព្រះជាម្ចាស់ចាត់ឲ្យយាងមក ថ្លែង
ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រោះព្រះជាម្ចាស់
ប្រទានព្រះវិញ្ញាណមកព្រះអង្គ យ៉ាងបរិបូណ៌។ ៣៥
ព្រះបិតាស្រឡាញ់ព្រះបុត្រា ហើយបានប្រគល់អ្វីៗ
ទាំងអស់ ឲ្យនៅក្រោមអំណាចរបស់ព្រះបុត្រា។ ៣៦
អ្នកណាជឿលើព្រះបុត្រា អ្នកនោះមានជីវិតអស់
កល្បជានិច្ច។ អ្នកណាមិនព្រមជឿលើព្រះបុត្រា អ្នក
នោះមិនបានទទួលជីវិតឡើយ គឺគេត្រូវទទួលទោស
ពីព្រះជាម្ចាស់»។

## ព្រះយេស៊ូសន្ទនាជាមួយស្ត្រីសាសន៍សាម៉ារីម្នាក់

១ព្រះយេស៊ូជ្រាបថា ពួកខាងគណៈផារីស៊ីបានឮគេ
៤និយាយថា ព្រះអង្គមានសាវ័ក*ច្រើនជាងលោកយ៉ូ
ហាន និងបានជ្រមុជទឹកឲ្យមនុស្សច្រើនជាងដែរ។ ២
តាមពិតព្រះយេស៊ូពុំបានជ្រមុជទឹកឲ្យគេផ្ទាល់ព្រះ
អង្គឡើយ គឺពួកសាវ័កវិញទេដែលជាអ្នកជ្រមុជទឹក។
៣ព្រះអង្គក៏យាងចាកចេញពីស្រុកយូដា ត្រឡប់ទៅ
ស្រុកកាលីឡេវិញ ៤ហើយត្រូវយាងកាត់តាមស្រុក
សាម៉ារី។

៥ព្រះអង្គបានយាងមកដល់ភូមិមួយ របស់ជន
ជាតិសាម៉ារី ឈ្មោះភូមិស៊ីខា នៅជិតចំការដែល
លោកយ៉ាកុបបានចែកឲ្យលោកយ៉ូសែប ជាកូន។ ៦
នៅទីនោះមានអណ្ដូងទឹកមួយ ឈ្មោះ"អណ្ដូងលោក
យ៉ាកុប"។ ព្រះយេស៊ូអស់កម្លាំងក្នុងការធ្វើដំណើរក៏
គង់នៅមាត់អណ្ដូង ពេលនោះប្រហែលជាថ្ងៃត្រង់។
៧មានស្ត្រីសាសន៍សាម៉ារីម្នាក់មកដងទឹក ព្រះយេស៊ូ
មានព្រះបន្ទូលទៅនាងថា៖«ខ្ញុំសុំទឹកទទួលទាន
បន្តិច»។ ៨(សាវ័កនាំគ្នាទៅរកទិញស្បៀងអាហារ
នៅឯភូមិ)។ ៩ស្ត្រីសាម៉ារីទូលព្រះអង្គថា៖ «លោក
ជាសាសន៍យូដាម្ដេចក៏លោកមកសុំទឹកនាងខ្ញុំ ជាស្ត្រី
សាសន៍សាម៉ារីពិសាដូច្នេះ?» (ដ្បិតសាសន៍យូដា
និងសាសន៍សាម៉ារីមិនត្រូវគ្នាទេ)។ ១០ព្រះយេស៊ូ
មានព្រះបន្ទូលតប ទៅនាងថា៖ «ប្រសិនបើ នាង
ស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ និង
ស្គាល់អ្នកដែលនិយាយទៅកាន់នាងថា "ខ្ញុំសុំទឹក
ទទួលទានបន្តិច" នោះនាងមុខជាសុំទឹកពីលោកវិញ
ពុំខាន ហើយលោកនឹងឲ្យទឹកដល់នាង គឺជាទឹក

ដែលផ្ដល់ជីវិត»[ប]។ ១១នាងទូលព្រះអង្គថា៖ «លោក
ម្ចាស់! លោកគ្មានអ្វីដងទឹកសោះ រីឯអណ្ដូងសោតក៏
ជ្រៅទៀតផង តើលោកបានទឹកដែលផ្ដល់ជីវិតនោះពី
ណាមក?។ ១២តើលោកមានឋានៈធំជាងលោកយ៉ា
កុប ជាបុព្វបុរស*របស់យើង ដែលបានទុកអណ្ដូង
នេះឲ្យយើងឬ?។ លោកយ៉ាកុបនិងកូនចៅរបស់
លោកបានពិសាទឹកអណ្ដូងនេះ ហើយសត្វរបស់
លោកក៏បានផឹកទឹកអណ្ដូងនេះដែរ»។ ១៣ព្រះយេស៊ូ
មានព្រះបន្ទូលទៅនាងថា៖ «អស់អ្នកដែលពិសាទឹក
នេះនៅតែស្រេកតទៅមុខទៀត ១៤រីឯអ្នកដែលពិសា
ទឹកខ្ញុំឲ្យនោះ នឹងមិនស្រេកទៀតសោះឡើយ ដ្បិត
ទឹកខ្ញុំឲ្យនឹងបានទៅជាប្រភពទឹកដែលផុសឡើងផ្ដល់
ជីវិតអស់កល្បជានិច្ច»។ ១៥ស្ត្រីនោះទូលព្រះអង្គថា៖
«លោកម្ចាស់! សូមមេត្តាផ្ដល់ទឹកនោះមកនាងខ្ញុំផង
កុំឲ្យនាងខ្ញុំស្រេក និងកុំឲ្យរវល់មកដងទឹកអណ្ដូងនេះ
ទៀត»។

១៦ព្រះអង្គមានព្រះបន្ទូលទៅនាងថា៖ «សុំ
អញ្ជើញទៅហៅប្ដីនាង រួចត្រឡប់មកវិញ»។ ១៧ស្ត្រី
នោះទូលព្រះអង្គថា៖ «នាងខ្ញុំគ្មានប្ដីទេ»។ ព្រះ
យេស៊ូមានព្រះបន្ទូលថា៖ «នាងនិយាយថា នាង
គ្មានប្ដីដូច្នេះ ត្រូវមែន ១៨ព្រោះនាងធ្លាប់មានប្ដីប្រាំមក
ហើយ រីឯបុរសដែលនៅជាមួយនាងសព្វថ្ងៃមិនមែន
ជាប្ដីរបស់នាងទេ នាងនិយាយត្រង់មែន»។ ១៩នាង
ទូលព្រះអង្គថា៖ «លោកម្ចាស់នាងខ្ញុំយល់ថា លោក
ពិតជាព្យាការី*មែន។ ២០បុព្វបុរសរបស់យើងនាំគ្នា
ថ្វាយបង្គំព្រះជាម្ចាស់នៅលើភ្នំនេះ តែពួកលោកជា
សាសន៍យូដាតែងនិយាយថា ត្រូវថ្វាយបង្គំព្រះអង្គ
នៅក្រុងយេរូសាឡឹមវិញ»។ ២១ព្រះយេស៊ូមានព្រះ
បន្ទូលទៅនាងថា៖ «នាងអើយ ជឿខ្ញុំចុះដល់ពេល
កំណត់មិនមែននៅលើភ្នំនេះ ឬនៅក្រុងយេរូសាឡឹម
ទៀតទេ ដែលអ្នករាល់គ្នានឹងថ្វាយបង្គំព្រះបិតា។ ២២
អ្នករាល់គ្នាមិនស្គាល់ព្រះអង្គ ដែលអ្នករាល់គ្នាថ្វាយ
បង្គំទេ រីឯយើងវិញយើងស្គាល់ព្រះអង្គដែលយើង
ថ្វាយបង្គំ ដ្បិតការសង្គ្រោះចេញមកពីជនជាតិយូដា។
២៣ប៉ុន្តែដល់ពេលកំណត់ គឺឥឡូវហ្នឹងហើយ អ្នក
ថ្វាយបង្គំដ៏ពិតប្រាកដនឹងថ្វាយបង្គំព្រះបិតាតាម
វិញ្ញាណនិងតាមសេចក្ដីពិត ដ្បិតព្រះបិតាសព្វព្រះហ
ឫទ័យនឹងអ្នកថ្វាយបង្គំ បែបនេះឯង។ ២៤ព្រះជា
ម្ចាស់ជាវិញ្ញាណហេតុនេះ អស់អ្នកដែលថ្វាយបង្គំ
ព្រះអង្គ ត្រូវតែថ្វាយបង្គំតាមវិញ្ញាណនិងតាមសេចក្ដី
ពិត»។ ២៥ស្ត្រីនោះទូលព្រះអង្គថា៖ «នាងខ្ញុំដឹង
ហើយថា ព្រះមេស្ស៊ីហៅព្រះគ្រីស្ត*នឹងយាងមក។
កាលណាព្រះអង្គយាងមកដល់ ទ្រង់នឹងប្រទានឲ្យ
យើងដឹងសព្វគ្រប់ទាំងអស់»។ ២៦ព្រះយេស៊ូមាន
ព្រះបន្ទូលទៅនាងថា៖ «ខ្ញុំនេះហើយ គឺខ្ញុំដែលកំពុង
តែនិយាយជាមួយនាង»។

២៧ពេលនោះ ពួកសាវ័កត្រឡប់មកដល់ ឃើញ
ព្រះអង្គកំពុងនិយាយជាមួយស្ត្រីដូច្នេះ គេងឿងឆ្ងល់
ជាខ្លាំង តែគ្មាននរណាទូលសួរព្រះអង្គថា ព្រះអង្គសួរ
រកអ្វី ឬហេតុដូចម្ដេចក៏មានព្រះបន្ទូលជាមួយនាងឡើ
យ។ ២៨ស្ត្រីនោះទុកក្អមចោល រត់ចូលទៅក្នុងភូមិ
ប្រាប់អ្នកស្រុកថា៖ ២៩«សុំមកមើលបុរសម្នាក់ លោក
មានប្រសាសន៍ប្រាប់ខ្ញុំនូវអំពើទាំងប៉ុន្មាន ដែលខ្ញុំ
បានប្រព្រឹត្ត។ លោកនោះជាព្រះគ្រីស្តហើយមើល
ទៅ!»។ ៣០អ្នកស្រុកនាំគ្នាចេញពីភូមិទៅរកព្រះយេ
ស៊ូ។ ៣១ក្នុងពេលជាមួយគ្នានោះ ពួកសាវ័កទូលព្រះ
អង្គថា៖ «លោកគ្រូ សូមអញ្ជើញពិសា!»។ ៣២ព្រះ
អង្គមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំមានអាហារ
បរិភោគហើយ ជាអាហារដែលអ្នករាល់គ្នាពុំស្គាល់»
។ ៣៣ពួកសាវ័កក៏និយាយគ្នាថា៖ «ប្រហែលជាមាន
នរណាម្នាក់ យកអាហារមកជូនលោកហើយទេ
ដឹង?»។ ៣៤ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «
អាហាររបស់ខ្ញុំ គឺធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ
ដែលបានចាត់ខ្ញុំឲ្យមក ព្រមទាំងបង្ហើយកិច្ចការរបស់

ព្រះអង្គ ឲ្យបានសម្រេច។៣៥អ្នករាល់គ្នាតែងពោល
ថា "បួនខែទៀតដល់រដូវចម្រូត"។ រីឯខ្ញុំវិញ ខ្ញុំសុំ
ប្រាប់អ្នករាល់គ្នាថា ចូរមើលទៅវាលស្រែមើល៍ ស្រូវ
ទុំល្អមច្រូតហើយ។ ៣៦អ្នកច្រូតបានប្រាក់ឈ្នួលរបស់
ខ្លួន ហើយកំពុងប្រមូលផល ទុកសម្រាប់ជីវិតអស់
កល្បជានិច្ចដូច្នេះ អ្នកសាបព្រោះ និងអ្នកច្រូតកាត់
បានសប្បាយរួមជាមួយគ្នា ៣៧ស្របតាមពាក្យចាស់
លោកថា៖ "ម្នាក់ព្រោះ ម្នាក់ទៀតច្រូត"។ ៣៨ខ្ញុំបាន
ចាត់អ្នករាល់គ្នា ឲ្យទៅច្រូតនៅក្នុងស្រែដែលអ្នករាល់
គ្នាពុំបានធ្វើការនឿយហត់ គឺអ្នកផ្សេងទៀតបានធ្វើ
ការនឿយហត់ហើយអ្នករាល់គ្នាទទួលផលពីការ
នឿយហត់របស់អ្នកទាំងនោះ»។

៣៩ក្នុងភូមិនោះ មានអ្នកស្រុកសាម៉ារីជាច្រើន
បានជឿលើព្រះយេស៊ូ ដោយសារពាក្យដែលស្ត្រី
នោះបានបញ្ជាក់ប្រាប់ថា "លោកមានប្រសាសន៍
ប្រាប់ខ្ញុំនូវអំពើទាំងប៉ុន្មាន ដែលខ្ញុំបានប្រព្រឹត្ត"។៤០
ហេតុនេះហើយបានជា កាលជនជាតិសាម៉ារីទៅ
គាល់ព្រះអង្គ គេអង្វរសូមព្រះអង្គគង់នៅជាមួយគេ
ព្រះអង្គយល់ព្រមគង់នៅទីនោះពីរថ្ងៃ។ ៤១មាន
មនុស្សច្រើនជាងនោះទៅទៀត បានជឿលើព្រះអង្គ
ដោយបានឮព្រះបន្ទូលព្រះអង្គផ្ទាល់។ ៤២ពួកគេ
និយាយទៅកាន់ស្ត្រីនោះថា៖ «ឥឡូវនេះយើងជឿ
មិនមែនត្រឹមតែឮពាក្យនាងប៉ុណ្ណោះទេ គឺមកពីយើង
បានឮ ព្រះអង្គមានព្រះបន្ទូលផ្ទាល់នឹងត្រចៀកថែម
ទៀតផង ហើយយើងដឹងថា ព្រះអង្គពិតជាព្រះស
ង្គ្រោះរបស់មនុស្សលោកមែន»។

## ព្រះយេស៊ូប្រោសកូនប្រុសរបស់មន្ត្រីម្នាក់ឲ្យបានជា

៤៣ពីរថ្ងៃក្រោយមក ព្រះយេស៊ូយាងចាកចេញ
ពីទីនោះឆ្ពោះទៅកាន់ស្រុកកាលីឡេ។ ៤៤ព្រះអង្គ
មានព្រះបន្ទូលថា៖ «គ្មានព្យាការីណាម្នាក់ត្រូវគេ
គោរព ក្នុងស្រុកកំណើតរបស់ខ្លួនផ្ទាល់ឡើយ»។៤៥
លុះព្រះអង្គយាងទៅដល់ស្រុកកាលីឡេ អ្នកស្រុកនាំ
គ្នាទទួលព្រះអង្គ ព្រោះគេបានឃើញការអស្ចារ្យទាំង
ប៉ុន្មានដែលព្រះអង្គបានសម្ដែង ក្នុងឱកាសពិធីបុណ្យ
ចម្លង* នៅក្រុងយេរូសាឡឹម ដ្បិតគេក៏បានទៅចូល
រួមពិធីបុណ្យនោះដែរ។ ៤៦ព្រះអង្គយាងត្រឡប់ទៅ
ភូមិកាណា ក្នុងស្រុកកាលីឡេម្ដងទៀត ជាភូមិដែល
ព្រះអង្គបានធ្វើឲ្យ ទឹកទៅជាស្រាទំពាំងបាយជូរ។

នៅទីនោះ មានអ្នករាជការម្នាក់មកពីក្រុងកាផា
ណិម កូនប្រុសរបស់លោកមានជំងឺ។ ៤៧កាលលោក
ជ្រាបថា ព្រះយេស៊ូបានយាងពីស្រុកយូដាមកស្រុក
កាលីឡេនេះ លោកក៏ទៅរកព្រះអង្គទូលអង្វរសូម
ព្រះអង្គយាងទៅប្រោសកូនរបស់លោក ដែលកំពុង
តែឈឺជិតផុតដង្ហើមនោះ ឲ្យបានជាសះស្បើយ។ ៤៨
ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ប្រសិនបើ
អ្នករាល់គ្នាមិនបានឃើញទីសម្គាល់និងឫទ្ធិបាដិហារិ
យ៍ទេ អ្នករាល់គ្នាមុខជាមិនជឿឡើយ»។ ៤៩មន្ត្រី
នោះទូលព្រះអង្គថា៖ «លោកម្ចាស់អើយ សូមលោក
អញ្ជើញមកក្រែងកូនរបស់ខ្ញុំប្របាទស្លាប់»។ ៥០ព្រះ
យេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អញ្ជើញទៅចុះ
កូនរបស់លោករស់ហើយ»។ បុរសនោះជឿ ព្រះ
បន្ទូលរបស់ព្រះយេស៊ូក៏ចេញដំណើរទៅ។ ៥១ពេល
លោកកំពុងតែដើរតាមផ្លូវត្រឡប់ទៅផ្ទះវិញ ពួកបម្រើ
របស់លោកនាំគ្នាចេញមកជម្រាបថា កូនរបស់លោក
រស់ហើយ។ ៥២លោកក៏សួរអ្នកបម្រើឲ្យដឹងថា កូន
របស់លោកបានធូរស្បើយពីថ្មើរណា។ គេតបថា៖ «
កូនរបស់លោកបាត់គ្រុនពីម្សិលមិញ វេលាម៉ោងមួយ
រសៀល»។ ៥៣ឪពុកដឹងថា គឺនៅម៉ោងនោះឯងដែល
ព្រះយេស៊ូមានព្រះបន្ទូលមកគាត់ថា "កូនរបស់
លោករស់ហើយ!"។ លោកជឿលើព្រះយេស៊ូ ហើយ
ក្រុមគ្រួសាររបស់លោកទាំងមូល ក៏ជឿលើព្រះអង្គដែ
រ។ ៥៤នេះជាទីសម្គាល់លើកទីពីរ ដែលព្រះយេស៊ូ

បានធ្វើ នៅពេលដែលព្រះអង្គវិលត្រឡប់ពីស្រុកយូ
ជា មកស្រុកកាលីឡេវិញ។

## ព្រះយេស៊ូប្រោស មនុស្សពិការម្នាក់ឲ្យបានជា

១ក្រោយមកទៀត មានពិធីបុណ្យមួយរបស់ជនជាតិ
៥យូដា ព្រះយេស៊ូយាងឡើងទៅក្រុងយេរូសាឡឹម។
២នៅក្រុងយេរូសាឡឹមជិតខ្លោងទ្វារឈ្មោះ «ទ្វារ
ចៀម» មានស្រះមួយដែលគេហៅជាភាសាហេប្រឺថា
«ស្រះបេតសាថា» ក្បែរស្រះនោះមានថែវប្រាំ។ ៣
មានអ្នកជំងឺមនុស្សខ្វាក់មនុស្សខ្វិនមនុស្សខូចជើង
និងមនុស្សស្លាប់ដៃស្លាប់ជើងជាច្រើន ដេកនៅតាម
ថែវទាំងនោះ [ រង់ចាំ ទឹក កម្រើក ៤ដ្បិតយូរៗម្ដង
មានទេវទូត*មួយរូប ចុះមកធ្វើឲ្យទឹកស្រះកម្រើក
អ្នកណាចុះទៅក្នុងទឹកកម្រើកបានមុនគេ អ្នកនោះ
នឹងបានជា ទោះបីមានជំងឺអ្វីក៏ដោយ ]។ ៥នៅទីនោះ
មានបុរសម្នាក់ពិការ តាំងពីសាមសិបប្រាំបីឆ្នាំមកហើ
យ។ ៦ព្រះយេស៊ូទតឃើញគាត់ដេកដូច្នេះ ព្រះអង្គ
ជ្រាបថា គាត់នៅទីនោះជាយូរមកហើយ ទ្រង់មាន
ព្រះបន្ទូលសួរគាត់ថា៖ «តើអ្នកចង់ជាឬទេ?»។ ៧
អ្នកនោះទូលព្រះអង្គថា៖ «លោកម្ចាស់អើយ ពេល
ទឹកកម្រើក គ្មាននរណាយកខ្ញុំទៅដាក់ក្នុងស្រះសោះ
ហើយពេលណាខ្ញុំទៅដល់ មានម្នាក់ចុះទៅមុនខ្ញុំ
ស្រេចទៅហើយ»។ ៨ព្រះយេស៊ូមានព្រះបន្ទូលទៅ
គាត់ថា៖ «ចូរក្រោកឡើងយកគ្រែស្នែងរបស់អ្នក
ហើយដើរទៅចុះ»។ ៩ពេលនោះ ស្រាប់តែបុរសនោះ
បានជាភ្លាម គាត់ក៏យកគ្រែស្នែងរបស់គាត់ដើរទៅ។
១០រីឯថ្ងៃនោះជាថ្ងៃសប្ប័ទ* ជនជាតិយូដាស្ដីឲ្យបុរស
ដែលបានជានោះថា៖ «ថ្ងៃនេះជាថ្ងៃសប្ប័ទ អ្នកគ្មាន
សិទ្ធិលីគ្រែស្នែងរបស់អ្នកដូច្នេះឡើយ»។ ១១គាត់
ឆ្លើយទៅគេថា៖ «លោកដែលបានធ្វើឲ្យខ្ញុំជាប្រាប់ខ្ញុំ
ថា "ចូរយកគ្រែស្នែងរបស់អ្នកដើរទៅចុះ!"»។ ១២
គេសួរគាត់ថា៖ «តើលោកណាប្រាប់អ្នកឲ្យយកគ្រែ
ស្នែងដើរទៅដូច្នេះ?»។ ១៣ប៉ុន្តែបុរសដែលបានជា
មិនដឹងថា នរណាបានប្រោសគាត់ឲ្យជាឡើយ ដ្បិត
ព្រះយេស៊ូបានយាងចេញពីបណ្ដាជន ដែលនៅ
កន្លែងនោះផុតទៅហើយ។

១៤ក្រោយមក ព្រះយេស៊ូជួបគាត់ក្នុងព្រះវិហារ
ក៏មានព្រះបន្ទូលទៅគាត់ថា៖ «ឥឡូវនេះ អ្នកបានជា
ហើយកុំប្រព្រឹត្តអំពើបាបទៀតឲ្យសោះ ក្រែងលោ
កើតការអាក្រក់ដល់អ្នក លើសមុនទៅទៀត»។ ១៥
បុរសនោះចេញទៅប្រាប់ជនជាតិយូដា ឲ្យដឹងថាគឺ
ព្រះយេស៊ូដែលបានប្រោសគាត់ឲ្យជា។ ១៦ហេតុនេះ
ហើយ បានជាជនជាតិយូដានាំគ្នាបៀតបៀនព្រះ
យេស៊ូ ព្រោះព្រះអង្គធ្វើការនោះនៅថ្ងៃសប្ប័ទ។ ១៧
ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ព្រះបិតារបស់
ខ្ញុំធ្វើការរហូតមកទល់សព្វថ្ងៃ ខ្ញុំក៏ធ្វើការដូចព្រះអង្គ
ដែរ»។ ១៨កាលឮព្រះបន្ទូលនេះ ជនជាតិយូដារឹតតែ
ចង់ធ្វើគុតព្រះអង្គខ្លាំងឡើងៗ មិនមែនមកពីព្រះអង្គ
មិនបានគោរពតាមវិន័យ* សម្រាប់ថ្ងៃសប្ប័ទ
ប៉ុណ្ណោះទេ គឺមកពីព្រះអង្គមានព្រះបន្ទូលថា ព្រះជា
ម្ចាស់ជាព្រះបិតារបស់ព្រះអង្គផ្ទាល់ថែមទៀត ព្រះ
អង្គលើកខ្លួនឡើងស្មើនឹងព្រះជាម្ចាស់។

## អំណាចរបស់ព្រះយេស៊ូ

១៩ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំ
ប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ព្រះបុត្រាពុំអាចធ្វើអ្វី
ដោយព្រះអង្គផ្ទាល់បានឡើយ គឺព្រះបុត្រាធ្វើតែកិច្ច
ការណា ដែលទ្រង់បានឃើញព្រះបិតាធ្វើប៉ុណ្ណោះ។
កិច្ចការអ្វីដែលព្រះបិតាធ្វើព្រះបុត្រាក៏ធ្វើកិច្ចការនោះ
ដែរ។ ២០ព្រះបិតាមានព្រះហឫទ័យស្រឡាញ់ព្រះ
បុត្រា និងបង្ហាញឲ្យព្រះបុត្រាឃើញគ្រប់កិច្ចការដែល
ព្រះអង្គធ្វើ ព្រះបិតានឹងបង្ហាញឲ្យព្រះបុត្រា ឃើញ
កិច្ចការធំជាងនេះទៅទៀត ដើម្បីឲ្យអ្នករាល់គ្នាងឿង
ឆ្ងល់។ ២១ដូចព្រះបិតាប្រោសមនុស្សស្លាប់ឲ្យមាន

ជីវិតរស់ឡើងវិញ ព្រះបុត្រាប្រទានជីវិតឲ្យនរណាក៏
បាន ស្រេចតែនឹងព្រះហឫទ័យរបស់ព្រះអង្គ។ ២២
ព្រះបិតាមិនដាក់ទោសនរណាឡើយ គឺព្រះអង្គបាន
ប្រគល់អំណាចដាក់ទោសទាំងអស់ ឲ្យព្រះបុត្រាវិញ
២៣ដើម្បីឲ្យមនុស្សគ្រប់ៗគ្នាគោរពព្រះបុត្រា ដូចគេ
គោរពព្រះបិតា។ អ្នកណាមិនគោរពព្រះបុត្រាទេ អ្នក
នោះក៏មិនគោរពព្រះបិតា ដែលបានចាត់ព្រះបុត្រាឲ្យ
យាងមកនោះដែរ។ ២៤ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹង
ច្បាស់ថាអ្នកណាស្ដាប់សេចក្ដីដែលខ្ញុំនិយាយ ហើយ
ជឿលើព្រះអង្គដែលបានចាត់ខ្ញុំឲ្យមក អ្នកនោះមាន
ជីវិតអស់កល្បជានិច្ច គេមិនត្រូវទទួលទោសឡើយ
គឺបានឆ្លងផុតពីសេចក្ដីស្លាប់ទៅរកជីវិត។ ២៥ខ្ញុំសុំ
ប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ដល់ពេលកំណត់គឺ
ឥឡូវនេះហើយ មនុស្សស្លាប់នឹងឮព្រះសូរសៀងព្រះ
បុត្រារបស់ព្រះជាម្ចាស់ ហើយអស់អ្នកដែលឮព្រះ
សូរសៀងនោះ នឹងមានជីវិតរស់នៅ ២៦ដ្បិតព្រះបិតា
ជាប្រភពនៃជីវិតយ៉ាងណាព្រះអង្គក៏ប្រទានឲ្យព្រះ
បុត្រាធ្វើជាប្រភពនៃជីវិត យ៉ាងនោះដែរ ២៧ហើយ
ព្រះបិតាក៏ប្រទាន ឲ្យព្រះបុត្រាមានអំណាចដាក់
ទោសថែមទៀតផង ព្រោះព្រះបុត្រាជាបុត្រមនុស្ស*
។ ២៨សុំកុំងឿងឆ្ងល់ឡើយ ដ្បិតដល់ពេលកំណត់
មនុស្សស្លាប់ទាំងប៉ុន្មាននឹងឮព្រះសូរសៀងរបស់ព្រះ
បុត្រា ២៩ហើយចេញពីផ្នូរមក។ អ្នកដែលបានប្រព្រឹត្ត
អំពើល្អនឹងរស់ឡើងវិញ ដើម្បីទទួលជីវិត រីឯអ្នក
ដែលបានប្រព្រឹត្តអំពើអាក្រក់ នឹងរស់ឡើងវិញ ដើម្បី
ទទួលទោស»។

## សក្ខីភាពអំពីអំណាចរបស់ព្រះយេស៊ូ

៣០«ខ្ញុំមិនអាចធ្វើអ្វី ដោយអំណាចខ្ញុំផ្ទាល់បាន
ឡើយ ខ្ញុំវិនិច្ឆ័យគ្រប់ការទាំងអស់តាមសេចក្ដី ដែល
ព្រះបិតាមានព្រះបន្ទូលមកខ្ញុំ ហើយការវិនិច្ឆ័យរបស់
ខ្ញុំត្រឹមត្រូវ ព្រោះខ្ញុំមិនប្រាថ្នាធ្វើតាមបំណងចិត្តខ្ញុំ
ឡើយ គឺធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គដែលបាន
ចាត់ ឲ្យខ្ញុំមកនោះវិញ។ ៣១ប្រសិនបើខ្ញុំធ្វើជាបន្ទាល់
ឲ្យខ្លួនខ្ញុំផ្ទាល់ សក្ខីភាពរបស់ខ្ញុំមិនពិតទេ។ ៣២ប៉ុន្តែ
មានម្នាក់ទៀតធ្វើជាបន្ទាល់ឲ្យខ្ញុំហើយខ្ញុំដឹងថា សក្ខី
ភាពដែលអ្នកនោះថ្លែងអំពីខ្ញុំស្របតាមសេចក្ដីពិត។
៣៣អ្នករាល់គ្នាបានចាត់គេ ឲ្យទៅសួរលោកយ៉ូហាន
លោកក៏ផ្ដល់សក្ខីភាពអំពីសេចក្ដីពិត។ ៣៤ចំពោះខ្ញុំ ខ្ញុំ
មិនត្រូវការសក្ខីភាពពីមនុស្សណាឡើយ តែខ្ញុំពោល
ដូច្នេះ ដើម្បីឲ្យអ្នករាល់គ្នាទទួលការសង្គ្រោះ។ ៣៥
លោកយ៉ូហាននេះប្រៀបបាននឹងចង្កៀងដែលកំពុង
ឆេះបំភ្លឺ ហើយអ្នករាល់គ្នាក៏ចង់រីករាយនឹងពន្លឺនោះ
មួយស្របក់ដែរ។ ៣៦រីឯខ្ញុំវិញ ខ្ញុំមានសក្ខីភាពមួយ
ប្រសើរជាងសក្ខីភាពរបស់លោកយ៉ូហានទៅទៀត។
ព្រះបិតាប្រទានឲ្យខ្ញុំបង្ហើយកិច្ចការទាំងអំបាលម៉ាន
គឺកិច្ចការដែលខ្ញុំធ្វើនេះហើយជាសក្ខីភាពបញ្ជាក់ថា
ព្រះអង្គបានចាត់ខ្ញុំឲ្យមកមែន។ ៣៧ព្រះបិតាដែល
បានចាត់ខ្ញុំឲ្យមកក៏បានធ្វើជាបន្ទាល់ឲ្យខ្ញុំដែរ តែអ្នក
រាល់គ្នាមិនដែលបានឮព្រះសូរសៀងរបស់ព្រះអង្គ
ហើយក៏មិនដែលបានឃើញព្រះភ័ក្ត្ររបស់ព្រះអង្គផ
ង។ ៣៨អ្នករាល់គ្នាគ្មានព្រះបន្ទូលរបស់ព្រះអង្គ នៅ
ក្នុងចិត្តទេ ព្រោះអ្នករាល់គ្នាពុំជឿអ្នក ដែលព្រះបិតា
បានចាត់ឲ្យមក។ ៣៩អ្នករាល់គ្នាខំពិនិត្យពិច័យមើល
គម្ពីរ ព្រោះនឹកស្មានថា នឹងបានជីវិតអស់កល្បជានិច្ច
ដោយសារគម្ពីរទាំងនេះ គឺគម្ពីរនេះហើយធ្វើជា
បន្ទាល់ឲ្យខ្ញុំ ៤០ប៉ុន្តែ អ្នករាល់គ្នាមិនចង់មករកខ្ញុំដើម្បី
ឲ្យបានជីវិតឡើយ។ ៤១ខ្ញុំមិនចង់ទទួលសិរីរុងរឿងពី
មនុស្សទេ។ ៤២ម៉្យាងទៀតខ្ញុំស្គាល់ចិត្តអ្នករាល់គ្នា
ហើយអ្នករាល់គ្នា គ្មានចិត្តស្រឡាញ់ព្រះជាម្ចាស់
សោះ។ ៤៣ខ្ញុំមកក្នុងព្រះនាមព្រះបិតាខ្ញុំ តែអ្នករាល់
គ្នាមិនទទួលខ្ញុំឡើយ។ ប្រសិនបើមានម្នាក់ទៀត មក
ក្នុងនាមខ្លួនគេផ្ទាល់ អ្នករាល់គ្នាមុខជាទទួលគេមិន
ខាន! ៤៤តើឲ្យអ្នករាល់គ្នាអាចជឿដូចម្ដេចបាន បើ
អ្នករាល់គ្នាចូលចិត្តទទួលសិរីរុងរឿង តែពីគ្នាទៅវិញ
ទៅមកដូច្នេះ ហើយពុំស្វែងរកសិរីរុងរឿង ពីព្រះជា

ម្ចាស់តែមួយគត់សោះនោះ? ៤៥កុំនឹកស្មានថាខ្ញុំនឹង
ចោទប្រកាន់អ្នករាល់គ្នា នៅចំពោះព្រះភ័ក្ត្រព្រះបិតា
ឡើយ គឺលោកម៉ូសេជាទីសង្ឃឹមរបស់អ្នករាល់គ្នាវិញ
ទេ ដែលនឹងចោទប្រកាន់។ ៤៦ប្រសិនបើអ្នករាល់គ្នា
ជឿពាក្យលោកម៉ូសេ អ្នករាល់គ្នាមុខជាជឿខ្ញុំមិនខាន
ព្រោះលោកបានសរសេរទុកក្នុងគម្ពីរស្ដីអំពីខ្ញុំ ៤៧ប៉ុន្តែ
បើអ្នករាល់គ្នាមិនជឿសេចក្ដី ដែលលោកបានសរ
សេរទុកទៅហើយនោះ ធ្វើម្ដេចនឹងឲ្យអ្នករាល់គ្នាជឿ
ពាក្យរបស់ខ្ញុំបាន!»។

## ព្រះយេស៊ូប្រទាននំបុ័ងឲ្យមនុស្សប្រាំពាន់នាក់

(ម៉ាថាយ ១៤.១៣-២១ ម៉ាកុស ៦.៣០-៤៤
លូកា ៩. ១០-១៧)

១បន្ទាប់មក ព្រះយេស៊ូយាងទៅត្រើយខាងនាយស
៦មុទ្រកាលីឡេ ដែលមានឈ្មោះថាឮសមុទ្រទីបេរី
យ៉ាដ។ ២មានបណ្ដាជនច្រើនកុះករមកតាមព្រះអង្គ
ព្រោះគេបានឃើញទីសម្គាល់ដែលព្រះអង្គបានធ្វើ
ដោយប្រោសអ្នកជំងឺឲ្យជា។ ៣ព្រះយេស៊ូយាងឡើង
ទៅលើភ្នំ ហើយគង់នៅទីនោះជាមួយពួកសាវ័ក*។
៤ពេលនោះ បុណ្យចម្លង*ជាបុណ្យរបស់ជន
ជាតិយូដាកាន់តែខិតជិតណាស់ហើយ។ ៥ព្រះយេស៊ូ
ទតឃើញបណ្ដាជនមកតាមព្រះអង្គ ច្រើនកុះករ
យ៉ាងនេះ ទ្រង់មានព្រះបន្ទូលទៅលោកភីលីពថា៖ «
តើយើងទៅរកទិញអាហារឯណា មកចែកឲ្យអ្នកទាំង
នេះបរិភោគបាន?»។ ៦ព្រះអង្គមានព្រះបន្ទូលដូច្នេះ
ដើម្បីល្បងមើលចិត្តលោកភីលីពតាមពិតព្រះអង្គ
ជ្រាបអំពីកិច្ចការ ដែលព្រះអង្គបម្រុងនឹងធ្វើស្រេចទៅ
ហើយ។ ៧លោកភីលីពទូលថា៖ «ទោះបីយើងយក
ប្រាក់ពីររយដួង* ទៅទិញនំបុ័ងក៏មិនគ្រាន់ដែរ សូម្បី
តែម្នាក់មួយដុំតូចៗក៏មិនបានផង»។ ៨មានសាវ័ក
ម្នាក់ឈ្មោះអន់ទ្រេ ជាប្អូនរបស់លោកស៊ីម៉ូនសិលា
ទូលព្រះអង្គថា៖ ៩«នៅទីនេះក្មេងប្រុសម្នាក់មាននំ
បុ័ងប្រាំដុំ និងត្រីតូចៗពីរកន្ទុយ។ ប៉ុន្តែបើមានតែ
ប៉ុណ្ណឹងធ្វើម្ដេចនឹងឲ្យគ្រាន់ សម្រាប់មនុស្សដ៏ច្រើន
យ៉ាងនេះ?»។ ១០ព្រះយេស៊ូមានព្រះបន្ទូលថា៖ «សុំ
ឲ្យគេអង្គុយចុះ»។ នៅទីនោះមានស្មៅច្រើនបណ្ដា
ជនក៏នាំគ្នាអង្គុយ មានមនុស្សប្រុសទាំងអស់
ប្រមាណប្រាំពាន់នាក់។ ១១ព្រះយេស៊ូយកនំបុ័ងមក
កាន់អរព្រះគុណព្រះជាម្ចាស់ រួចប្រទានឲ្យអ្នកអង្គុយ
នៅទីនោះ។ រីឯត្រីវិញ ព្រះអង្គក៏ធ្វើដូច្នោះដែរ ទ្រង់
ប្រទានឲ្យគេតាមតែម្នាក់ៗចង់បាន។ ១២លុះគេបាន
បរិភោគឆ្អែតហើយ ព្រះយេស៊ូមានព្រះបន្ទូលទៅពួក
សាវ័កថា៖ «ចូរប្រមូលនំបុ័ងដែលនៅសល់ កុំឲ្យមាន
បាត់មួយដុំសោះឡើយ»។ ១៣ពួកសាវ័កនាំគ្នារើស
សំណល់នំបុ័ង ទាំងប្រាំដុំ ដែលបណ្ដាជនបរិភោគ
សល់ ប្រមូលដាក់បានពេញដប់ពីរល្អី។ ១៤កាល
មនុស្សម្នាឃើញទីសម្គាល់ ដែលព្រះយេស៊ូបានធ្វើ
នោះក៏ពោលថា៖ «លោកនេះពិតជាព្យាការី* ដែល
ត្រូវមកក្នុងពិភពលោកមែន»។ ១៥ព្រះយេស៊ូជ្រាបថា
គេបម្រុងនឹងចាប់ ព្រះអង្គយកទៅតែងតាំងជាស្ដេច
ដូច្នេះ ព្រះអង្គក៏យាងចាកចេញពីគេ ឡើងទៅលើភ្នំ
សាជាថ្មីតែមួយព្រះអង្គឯង។

## ព្រះយេស៊ូយាងលើទឹកសមុទ្រ

(ម៉ាថាយ ១៤.២២-៣៤ ម៉ាកុស ៦.៤៥-៥២)

១៦លុះដល់ល្ងាច ពួកសាវ័ក*នាំគ្នាចុះទៅមាត់
សមុទ្រ។ ១៧គេជិះទូកឆ្លងទៅក្រុងកាផានុម នៅ
ត្រើយម្ខាង។ ពេលនោះងងឹតហើយ តែព្រះយេស៊ូពុំ
ទាន់យាងមករកគេនៅឡើយទេ ១៨ខ្យល់បក់បោក
មកយ៉ាងខ្លាំង បណ្ដាលឲ្យទឹកសមុទ្រមានរលកធំៗ។
១៩កាលគេចែវទូកបានចម្ងាយប្រមាណជាប្រាំ ឬ
ប្រាំមួយគីឡូម៉ែត្រ ស្រាប់តែគេឃើញព្រះយេស៊ូយាង
លើសមុទ្រ ចូលមកជិតទូកគេភ័យខ្លាចជាខ្លាំង។ ២០

ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំទេតើ៎ កុំខ្លាចអី»។ ២១ពួកសាវ័កចង់យាងព្រះអង្គចូលមកក្នុងទូក រំពេចនោះទូកក៏ទៅដល់ត្រើយចំកន្លែង ដែលគេបម្រុងនឹងទៅ។

## ព្រះយេស៊ូជាអាហារដែលផ្តល់ជីវិត

២២ថ្ងៃបន្ទាប់មកទៀត បណ្តាជនដែលនៅត្រើយខាងនាយសមុទ្រ សង្កេតឃើញថា នៅកន្លែងនោះមានទូកតែមួយគត់ ហើយថា ព្រះយេស៊ូពុំបានយាងចុះទូកជាមួយពួកសាវ័ក*ទេ គឺមានតែពួកសាវ័កប៉ុណ្ណោះ ដែលបានជិះទូកចេញទៅ។ ២៣ប៉ុន្តែ មានទូកឯទៀតៗមកពីភូមិទីបេរីយ៉ាដ ចតនៅជិតកន្លែងដែលគេបានបរិភោគនំប៉័ង ក្រោយពីព្រះអម្ចាស់បានអរព្រះគុណ។ ២៤កាលបណ្តាជនពុំឃើញព្រះយេស៊ូ និងពួកសាវ័កនៅទីនោះទៀត គេក៏នាំគ្នាចុះទូកទាំងនោះ ឆ្លងទៅក្រុងកាផានុម តាមរកព្រះអង្គ។

២៥បណ្តាជនបានជួបព្រះអង្គ នៅត្រើយម្ខាង គេទូលសួរព្រះអង្គថា៖ «លោកគ្រូ! តើលោកមកដល់ពីអង្កាល់?»។ ២៦ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នករាល់គ្នាតាមរកខ្ញុំ មិនមែនមកពីអ្នករាល់គ្នាបានឃើញទីសម្គាល់ទេ គឺមកពីអ្នករាល់គ្នាបានបរិភោគអាហារឆ្អែតតែប៉ុណ្ណោះ។ ២៧កុំធ្វើកិច្ចការ ដើម្បីឲ្យគ្រាន់តែបានអាហារ ដែលតែងរលួយខូចនោះឡើយ គឺឲ្យបានអាហារដែលនៅស្ថិតស្ថេរ និងផ្តល់ជីវិតអស់កល្បជានិច្ចវិញ ជាអាហារដែលបុត្រមនុស្សនឹងប្រទានឲ្យអ្នករាល់គ្នា ដ្បិតបុត្រមនុស្សនេះហើយដែលព្រះជាម្ចាស់ជាព្រះបិតា បានដៅសញ្ញាសម្គាល់»។ ២៨គេនាំគ្នាទូលសួរព្រះអង្គថា៖ «តើឲ្យយើងខ្ញុំប្រព្រឹត្តដូចម្តេច ដើម្បីនឹងធ្វើកិច្ចការរបស់ព្រះជាម្ចាស់?»។ ២៩ព្រះយេស៊ូមានព្រះបន្ទូលថា៖ «កិច្ចការរបស់ព្រះជាម្ចាស់ គឺឲ្យអ្នករាល់គ្នាជឿលើអ្នកដែលព្រះអង្គបានចាត់ឲ្យមក»។ ៣០គេទូលសួរព្រះអង្គទៀតថា៖ «តើលោកធ្វើការអ្វីជាទីសម្គាល់ឲ្យយើងខ្ញុំឃើញ និងជឿលោក? តើលោកធ្វើកិច្ចការអ្វីខ្លះ?»។ ៣១បុព្វបុរសរបស់យើងបានបរិភោគនំម៉ាណានៅវាលរហោស្ថាន* ដូចមានសេចក្តីចែងទុកក្នុងគម្ពីរថា "ព្រះអង្គបានប្រទានឲ្យគេបរិភោគនំប៉័ងដែលធ្លាក់ពីស្ថានបរមសុខ*មក"»។ ៣២ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា មិនមែនលោកម៉ូសេទេ ដែលបានផ្តល់អាហារ ពីស្ថានបរមសុខមកនោះ គឺព្រះបិតារបស់ខ្ញុំទេតើ ដែលប្រទានអាហារដ៏ពិតប្រាកដពីស្ថានបរមសុខ* មកឲ្យអ្នករាល់គ្នា ៣៣ដ្បិតអាហារដែលព្រះជាម្ចាស់ប្រទានឲ្យនោះ គឺអ្នកដែលចុះពីស្ថានបរមសុខមក ហើយផ្តល់ជីវិតឲ្យមនុស្សលោក»។ ៣៤គេនាំគ្នាទូលព្រះអង្គថា៖ «លោកម្ចាស់អើយ! សូមលោកប្រទានអាហារនោះឲ្យយើងខ្ញុំរហូតតទៅ»។ ៣៥ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំនេះហើយជាអាហារដែលផ្តល់ជីវិត។ អ្នកណាមករកខ្ញុំ លែងឃ្លានទៀតហើយ អ្នកណាជឿលើខ្ញុំក៏លែងស្រេកទៀតដែរ។ ៣៦ប៉ុន្តែខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នារួចហើយថា "អ្នករាល់គ្នាបានឃើញខ្ញុំ តែអ្នករាល់គ្នាមិនជឿទេ"។ ៣៧អស់អ្នកដែលព្រះបិតាប្រទានមកខ្ញុំ តែងតែមករកខ្ញុំ ហើយខ្ញុំមិនបោះបង់ចោលអ្នកដែលមករកខ្ញុំជាដាច់ខាត ៣៨ដ្បិត ខ្ញុំចុះពីស្ថានបរមសុខមក ដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ដែលបានចាត់ខ្ញុំឲ្យមក គឺពុំមែនធ្វើតាមបំណងចិត្តរបស់ខ្ញុំទេ។ ៣៩រីឯព្រះអង្គដែលបានចាត់ខ្ញុំឲ្យមកនោះ ទ្រង់មិនសព្វព្រះហឫទ័យឲ្យនរណាម្នាក់ ក្នុងបណ្តាអស់អ្នកដែលព្រះអង្គប្រទានមកខ្ញុំ ត្រូវវិនាសអន្តរាយឡើយ តែព្រះអង្គសព្វព្រះហឫទ័យឲ្យខ្ញុំប្រោសគេ ឲ្យមានជីវិតរស់ឡើងវិញនៅថ្ងៃចុងក្រោយបំផុត។ ៤០ព្រះបិតារបស់ខ្ញុំសព្វព្រះហឫទ័យឲ្យអស់អ្នក ដែលបានឃើញព្រះ

បុត្រាហើយជឿលើព្រះអង្គ មានជីវិតអស់កល្បជានិច្ច។ ខ្ញុំនឹងប្រោសអ្នកនោះឲ្យមានជីវិតរស់ឡើងវិញនៅថ្ងៃចុងក្រោយបំផុតផង»។

៤១ជនជាតិយូដារអ៊ូរទាំអំពីព្រះយេស៊ូ ព្រោះព្រះអង្គមានព្រះបន្ទូលថា "ខ្ញុំជាអាហារដែលចុះមកពីស្ថានបរមសុខ*"។ ៤២គេពោលថា៖ «អ្នកនេះឈ្មោះយេស៊ូ ជាកូនរបស់លោកយ៉ូសែបទេតើ! យើងស្គាល់ទាំងឪពុកទាំងម្ដាយ ម្ដេចក៏គាត់ពោលថាគាត់ចុះមកពីស្ថានបរមសុខដូច្នេះ?»។ ៤៣ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ឈប់នាំគ្នារអ៊ូរទាំទៅ!។ ៤៤ប្រសិនបើព្រះបិតាដែលចាត់ខ្ញុំឲ្យមកមិនទាក់ទាញចិត្តគេទេ គ្មាននរណាម្នាក់អាចមករកខ្ញុំបានឡើយ។ រីឯខ្ញុំ ខ្ញុំនឹងប្រោសអ្នកនោះឲ្យមានជីវិតរស់ឡើងវិញនៅថ្ងៃចុងក្រោយបំផុត។ ៤៥ក្នុងគម្ពីរព្យាការីមានចែងទុកមកថា"ព្រះជាម្ចាស់ នឹងប្រៀនប្រដៅមនុស្សទាំងអស់"[ព]។ អស់អ្នកដែលបានស្ដាប់ព្រះបិតា ហើយទទួលយកការប្រៀនប្រដៅរបស់ព្រះអង្គ មុខជាមករកខ្ញុំពុំខាន។ ៤៦សេចក្ដីនេះពុំមែនមានន័យថា មាននរណាម្នាក់បានឃើញព្រះបិតាឡើយ លើកលែងតែអ្នកមកពីព្រះជាម្ចាស់ប៉ុណ្ណោះ គឺអ្នកនោះហើយដែលបានឃើញព្រះអង្គ។ ៤៧ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាជឿអ្នកនោះមានជីវិតអស់កល្បជានិច្ច។ ៤៨ខ្ញុំនេះហើយជាអាហារដែលផ្ដល់ជីវិត។ ៤៩បុព្វបុរសរបស់អ្នករាល់គ្នា បានបរិភោគនំម៉ាណា នៅវាលរហោស្ថាន ហើយទទួលមរណភាពអស់ទៅ។ ៥០រីឯអាហារដែលចុះមកពីស្ថានបរមសុខ មានប្រសិទ្ធភាពបែបនេះ គឺអ្នកណាបរិភោគ អ្នកនោះមិនស្លាប់ឡើយ។ ៥១ខ្ញុំនេះហើយជាអាហារ ដែលមានជីវិតចុះមកពីស្ថានបរមសុខ។ អ្នកណាបរិភោគអាហារនេះ នឹងរស់នៅអស់កល្បជានិច្ច។ អាហារដែលខ្ញុំនឹងឲ្យនោះ គឺខ្លួនខ្ញុំ[ភ]ផ្ទាល់ដែលត្រូវបូជាសម្រាប់ឲ្យមនុស្សលោកមានជីវិត»។

៥២ជនជាតិយូដាទាស់ទែងគ្នាយ៉ាងខ្លាំង ហើយគេនិយាយថា៖ «តើអ្នកនេះអាចឲ្យខ្លួនគាត់មកយើងបរិភោគដូចម្ដេចកើត?»។

៥៣ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ប្រសិនបើអ្នករាល់គ្នាមិនពិសាសាច់ និងលោហិតរបស់បុត្រមនុស្ស*ទេ អ្នករាល់គ្នាគ្មានជីវិតក្នុងខ្លួនឡើយ។៥៤អ្នកណាពិសាសាច់និងលោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំក៏នឹងប្រោសគេឲ្យមានជីវិតរស់ឡើងវិញ នៅថ្ងៃចុងក្រោយបំផុតផង។ ៥៥សាច់របស់ខ្ញុំជាអាហារដ៏ពិតប្រាកដ លោហិតរបស់ខ្ញុំក៏ជាភេសជ្ជៈដ៏ពិតប្រាកដដែរ។ ៥៦អ្នកណាពិសាសាច់និងលោហិតរបស់ខ្ញុំ អ្នកនោះស្ថិតនៅក្នុងខ្ញុំ ហើយខ្ញុំក៏ស្ថិតនៅក្នុងអ្នកនោះដែរ។ ៥៧ព្រះបិតាដែលបានចាត់ខ្ញុំឲ្យមក ទ្រង់មានព្រះជន្មរស់ ហើយខ្ញុំមានជីវិតដោយសារព្រះអង្គយ៉ាងណា អ្នកបរិភោគខ្ញុំ ក៏នឹងមានជីវិតរស់ដោយសារខ្ញុំយ៉ាងនោះដែរ។ ៥៨អាហារដែលបានចុះពីស្ថានបរមសុខមក មានប្រសិទ្ធភាពខុសពីអាហារ ដែលបុព្វបុរស*របស់អ្នករាល់គ្នាបានបរិភោគ ដ្បិតលោកទទួលមរណភាពអស់ទៅហើយ។ រីឯអ្នកដែលបរិភោគអាហារនេះនឹងរស់នៅអស់កល្បជានិច្ច»។

៥៩ព្រះយេស៊ូមានព្រះបន្ទូលទាំងនេះ នៅពេលព្រះអង្គបង្រៀនគេ ក្នុងធម្មសាលា* នៅក្រុងកាផានុម។ ៦០ក្រោយពីបានស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គហើយ ក្នុងចំណោមសាវ័ក*មានគ្នាច្រើនពោលថា៖ «ពាក្យទាំងនេះទាស់ត្រចៀកណាស់តើនរណាអាចទ្រាំស្ដាប់បាន?»។ ៦១ព្រះយេស៊ូឈ្វេងយល់ថា ពួកសាវ័ករអ៊ូរទាំពីពាក្យទាំងនេះ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «តើពាក្យទាំងនេះនាំឲ្យអ្នករាល់គ្នារវាតចិត្ត បាត់ជំនឿឬ? ៦២ចុះបើអ្នករាល់គ្នាឃើញបុត្រមនុស្ស* ឡើងទៅស្ថានដែលលោកនៅពីមុនវិញ តើ

ចិត្តអ្នករាល់គ្នានឹងទៅជាយ៉ាងណា?។ ៦៣មានតែព្រះ
វិញ្ញាណទេដែលផ្ដល់ជីវិត និស្ស័យលោកីយ៍មិនអាច
ផ្ដល់ជីវិតបានឡើយ។ រីឯពាក្យទាំងប៉ុន្មានដែលខ្ញុំ
បាននិយាយប្រាប់អ្នករាល់គ្នា សុទ្ធតែចេញមកពីព្រះ
វិញ្ញាណ ដែលផ្ដល់ជីវិត។ ៦៤ប៉ុន្តែក្នុងចំណោមអ្នក
រាល់គ្នា អ្នកខ្លះគ្មានជំនឿទេ»។ តាំងពីដើមដំបូងមក
ព្រះយេស៊ូស្គាល់អស់អ្នកដែលគ្មានជំនឿ ព្រមទាំង
ស្គាល់អ្នកដែលនឹងក្បត់ព្រះអង្គ រួចស្រេចទៅហើយ។
៦៥ព្រះអង្គមានព្រះបន្ទូលទៀតថា៖ «ហេតុនេះ បាន
ជាខ្ញុំប្រាប់អ្នករាល់គ្នារួចមកហើយថា ប្រសិនបើព្រះ
បិតាមិនប្រោសប្រទានទេនោះ គ្មាននរណាអាចមក
រកខ្ញុំបានឡើយ»។ ៦៦ចាប់ពីពេលនោះ មកក្នុង
ចំណោមសាវ័កមានគ្នាច្រើនដកខ្លួនថយ ឈប់តាម
ព្រះអង្គទៀត។ ៦៧ព្រះយេស៊ូក៏មានព្រះបន្ទូលសួរសា
វ័កទាំងដប់ពីររូបថា៖ «ចុះអ្នករាល់គ្នាវិញ តើអ្នករាល់
គ្នាចង់ចេញទៅដែរឬ?»។ ៦៨លោកស៊ីម៉ូនសិលា
ទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់ តើឲ្យយើងខ្ញុំ
ទៅរកនរណាវិញ? ព្រះបន្ទូលរបស់ព្រះអង្គផ្ដល់ជីវិត
អស់កល្បជានិច្ច។ ៦៩យើងខ្ញុំជឿហើយដឹងថា ព្រះ
អង្គពិតជាព្រះដ៏វិសុទ្ធ ដែលព្រះជាម្ចាស់ចាត់ឲ្យមក
យ»។ ៧០ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «គឺខ្ញុំ
ផ្ទាល់ដែលបានជ្រើសរើសអ្នកទាំងដប់ពីរមក ក៏ប៉ុន្តែ
ក្នុងចំណោមអ្នករាល់គ្នាមានម្នាក់ជាមារ»។ ៧១ព្រះ
អង្គមានព្រះបន្ទូលសំដៅទៅលើយូដា ជាកូនលោក
ស៊ីម៉ូនអ៊ីស្ការីយ៉ុត។ យូដានេះហើយដែលនឹងក្បត់
ព្រះអង្គ ទោះបីគាត់ជាសាវ័កមួយរូប ក្នុងចំណោមសា
វ័កទាំងដប់ពីរក៏ដោយ។

## ព្រះញាតិវង្សព្រះយេស៊ូមិនជឿលើព្រះអង្គ

១ក្រោយមក ព្រះយេស៊ូយាងចុះឡើងកាត់ស្រុកកា
លីឡេ ដ្បិតព្រះអង្គមិនសព្វព្រះហឫទ័យយាងទៅ
ស្រុកយូដាឡើយ ព្រោះជនជាតិយូដារកធ្វើគុតព្រះអ
ង្គ។ ២ពេលនោះ ជិតដល់ថ្ងៃបុណ្យមួយរបស់ជនជាតិ
យូដា ឈ្មោះបុណ្យបារាំ*។ ៣បងប្អូនព្រះយេស៊ូទូល
ព្រះអង្គថា៖ «សូមបងចាកចេញពីទីនេះទៅស្រុកយូ
ដាទៅ ដើម្បីឲ្យសិស្សរបស់បងឃើញកិច្ចការដែល
បងធ្វើ។ ៤អ្នកដែលចង់ឲ្យគេស្គាល់ខ្លួន មិនធ្វើការអ្វី
ដោយលាក់កំបាំងឡើយ។ បើបងធ្វើការអស្ចារ្យយ៉ាង
នេះ ត្រូវបង្ហាញឲ្យមនុស្សលោកឃើញផង»។ ៥បង
ប្អូនរបស់ព្រះយេស៊ូពុំជឿលើព្រះអង្គទេ។ ៦ព្រះ
យេស៊ូមានព្រះបន្ទូលទៅគេថា៖ «ពេលកំណត់របស់
បង មិនទាន់មកដល់នៅឡើយទេ។ រីឯប្អូនៗវិញ ចង់
ធ្វើអ្វីពេលណាក៏បាន។ ៧មនុស្សលោកមិនអាចស្អប់
ប្អូនៗបានឡើយ ប៉ុន្តែគេស្អប់បង ព្រោះបងបាន
បញ្ជាក់ប្រាប់ថា អំពើដែលគេប្រព្រឹត្តសុទ្ធតែអាក្រក់។
៨ចូរប្អូនៗឡើងទៅចូលរួមក្នុងពិធីបុណ្យទៅ បងមិន
ឡើងទៅទេ ព្រោះពេលកំណត់របស់បង មិនទាន់មក
ដល់នៅឡើយ»។ ៩ព្រះយេស៊ូមានព្រះបន្ទូលដូច្នោះ
ហើយ ព្រះអង្គក៏គង់នៅក្នុងស្រុកកាលីឡេតទៅទៀ
ត។

## ព្រះយេស៊ូនៅក្រុងយេរូសាឡឹមក្នុងឱកាសពិធីបុណ្យ

១០កាលប្អូនៗរបស់ព្រះយេស៊ូ ធ្វើដំណើរទៅ
ចូលរួមពិធីបុណ្យផុតអស់ទៅ ព្រះអង្គក៏យាងឡើង
ទៅដែរ ប៉ុន្តែទ្រង់យាងទៅស្ងាត់ៗមិនឲ្យនរណា
ឃើញឡើយ។ ១១ក្នុងឱកាសបុណ្យនោះជនជាតិយូ
ដាតាមរកព្រះយេស៊ូ គេសួរគ្នាថា៖ «តើលោកនៅ
ឯណា?»។ ១២បណ្ដាជនខ្សឹបខ្សៀវគ្នាជាច្រើនស្ដីអំពី
ព្រះអង្គខ្លះថា «លោកនោះជាមនុស្សល្អ» ខ្លះទៀត
ថា «ទេ អ្នកនោះជាអ្នកបញ្ឆោតបណ្ដាជន»។ ១៣
ប៉ុន្តែ គ្មាននរណាហ៊ាននិយាយអំពីព្រះអង្គដោយចំហ
ឡើយ ព្រោះគេខ្លាចសាសន៍យូដា។ ១៤លុះដល់ពាក់
កណ្ដាលពិធីបុណ្យ ព្រះយេស៊ូយាងឡើងទៅព្រះ
វិហារ* ហើយបង្រៀនបណ្ដាជន។ ១៥ជនជាតិយូដា

ងឿងឆ្ងល់ជាខ្លាំង គេពោលថា៖«អ្នកនេះមិនបាន
រៀនសូត្រអ្វីសោះ ចុះម្ដេចបានជាគាត់ចេះដឹងជ្រៅ
ជ្រះដូច្នេះ?»។ ១៦ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា
៖ «សេចក្ដីដែលខ្ញុំបង្រៀន មិនមែនចេញពីខ្ញុំទេ គឺ
ចេញពីព្រះជាម្ចាស់ ដែលបានចាត់ខ្ញុំឲ្យមក។១៧អ្នក
ដែលចង់ធ្វើតាមព្រះហឫទ័យ របស់ព្រះជាម្ចាស់
មុខជាដឹងថា សេចក្ដីដែលខ្ញុំបង្រៀននេះមកពីព្រះ
អង្គ ឬមកពីខ្ញុំផ្ទាល់មិនខាន។ ១៨អ្នកណានិយាយ
ដោយសំអាងលើខ្លួនផ្ទាល់ អ្នកនោះរកកិត្តិយស
សម្រាប់តែខ្លួនឯងប៉ុណ្ណោះ។ រីឯអ្នកដែលរកតែសិរីរុង
រឿងរបស់ព្រះអង្គ ដែលចាត់ខ្លួនឲ្យមកនិយាយតែ
សេចក្ដីពិត ឥតកុហកឡើយ។១៩លោកម៉ូសេប្រគល់វិ
ន័យទុកឲ្យអ្នករាល់គ្នា រួចស្រេចហើយ ប៉ុន្តែក្នុង
ចំណោមអ្នករាល់គ្នា គ្មាននរណាម្នាក់ប្រតិបត្តិតាមវិ
ន័យនោះទេ។ ហេតុអ្វីបានជាអ្នករាល់គ្នារកសម្លាប់ខ្ញុំ
ដូច្នេះ?»។ ២០បណ្ដាជនតបទៅព្រះអង្គថា៖ «លោក
ពិតជាមានខ្មោចចូលហើយ បានជានិយាយដូច្នេះ តើ
នរណារកសម្លាប់លោក?»។ ២១ព្រះយេស៊ូមានព្រះ
បន្ទូលទៅគេថា៖ «ខ្ញុំបានធ្វើកិច្ចការតែមួយ ហើយ
អ្នកទាំងអស់គ្នា បែរជាងឿងឆ្ងល់ទៅវិញ។ ២២លោក
ម៉ូសេ*បានបង្គាប់អ្នករាល់គ្នា ឲ្យធ្វើពិធីកាត់ស្បែក*
(តាមពិតគឺបុព្វបុរស*របស់អ្នករាល់គ្នាឯណោះ ជា
អ្នកបង្គាប់ឲ្យធ្វើពិធីនេះ មិនមែនលោកម៉ូសេទេ)
ហើយអ្នករាល់គ្នាធ្វើពិធីកាត់ស្បែក នៅថ្ងៃសប្ប័ទ*។
២៣បើអ្នករាល់គ្នាធ្វើពិធីកាត់ស្បែកនៅថ្ងៃសប្ប័ទ តែ
ឥតបំពានលើវិន័យរបស់លោកម៉ូសេទេនោះ ចុះ
ហេតុដូចម្ដេចបានជាអ្នករាល់គ្នាខឹងខ្ញុំ ដែលបាន
ប្រោសមនុស្សមួយទាំងមូល ឲ្យបានជានៅថ្ងៃសប្ប័ទ
ដូច្នេះ? ២៤កុំនាំគ្នាវិនិច្ឆ័យដោយគ្រាន់តែឃើញផ្នែក
ខាងក្រៅនោះឡើយ ចូរវិនិច្ឆ័យឲ្យបានត្រឹមត្រូវវិញ»
។

## ព្រះយេស៊ូជាព្រះគ្រិស្តមែនឬ?

២៥មានអ្នកក្រុងយេរូសាឡឹមខ្លះពោលថា៖ «លោក
នេះហើយដែលគេរកសម្លាប់ ២៦ឥឡូវនេះលោក
និយាយដោយចេញមុខ ចុះម្ដេចបានជាគ្មាននរណា
ថាអ្វីលោកដូច្នេះ?។ ប្រហែលអ្នកដឹកនាំរបស់យើង
ទទួលស្គាល់ថា លោកពិតជាព្រះគ្រិស្ត*ទេដឹង ២៧
ប៉ុន្តែ ពេលព្រះគ្រិស្តយាងមក គ្មាននរណាដឹងថាទ្រង់
យាងមកពីណាទេ។ រីឯលោកនេះវិញ យើងដឹង
ហើយថា គាត់មកពីណា»។ ២៨ពេលនោះ ព្រះ
យេស៊ូបង្រៀនបណ្ដាជនក្នុងព្រះវិហារ* ព្រះអង្គបន្លឺ
ព្រះសូរសៀងខ្លាំងៗថា៖ «អ្នករាល់គ្នាថាស្គាល់ខ្ញុំ
ហើយដឹងថា ខ្ញុំមកពីណាទៀត!។ ក៏ប៉ុន្តែ ខ្ញុំមិនមែន
មកក្នុងនាមខ្ញុំឡើយព្រះអង្គដែលចាត់ខ្ញុំឲ្យមក ទ្រង់
សម្ដែងសេចក្ដីពិតតែអ្នករាល់គ្នាមិនស្គាល់ព្រះអង្គ
ទេ។ ២៩រីឯខ្ញុំវិញខ្ញុំស្គាល់ព្រះអង្គ ព្រោះខ្ញុំចេញមកពី
ព្រះអង្គហើយទ្រង់បានចាត់ខ្ញុំឲ្យមក»។
៣០ពេលនោះ ពួកគេរកចាប់ព្រះយេស៊ូ ប៉ុន្តែ
គ្មាននរណាហ៊ានលូកដៃចាប់ព្រះអង្គទេ ព្រោះពេល
កំណត់របស់ព្រះអង្គ ពុំទាន់បានមកដល់នៅឡើយ។
៣១ក្នុងចំណោមបណ្ដាជន មានមនុស្សជាច្រើនបាន
ជឿលើព្រះយេស៊ូ គេពោលថា៖ «ពេលព្រះគ្រិស្ត
យាងមក តើព្រះអង្គនឹងសម្ដែងទីសម្គាល់ច្រើនជាង
លោកនេះឬ?»។

## គេចាត់កងរក្សាព្រះវិហារឲ្យមកចាប់ព្រះយេស៊ូ

៣២ពួកខាងគណៈផារីស៊ី* បានដឹងសេចក្ដីទាំង
អស់ ដែលបណ្ដាជនខ្សឹបខ្សៀវគ្នាអំពីព្រះយេស៊ូ។
ពេលនោះពួកនាយកបូជាចារ្យ* និងពួកខាងគណៈ
ផារីស៊ីក៏ចាត់កងរក្សាព្រះវិហារ*ឲ្យមកចាប់ព្រះអង្គ។
៣៣ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំនៅជាមួយអ្នក
រាល់គ្នា តែមួយរយៈពេលដ៏ខ្លីទៀតប៉ុណ្ណោះ បន្ទាប់

មក ខ្ញុំនឹងទៅឯព្រះអង្គដែលបានចាត់ខ្ញុំឲ្យមកនោះ
វិញហើយ។ ៣៤អ្នករាល់គ្នានឹងតាមរកខ្ញុំ តែរកមិន
ឃើញទេ ដ្បិតអ្នករាល់គ្នាពុំអាចទៅកន្លែងដែលខ្ញុំនៅ
នោះ បានឡើយ»។ ៣៥ជនជាតិយូដាសួរគ្នាថា៖ «
តើគាត់បម្រុងទៅណា បានជាយើងពុំអាចនឹងរកគាត់
ឃើញដូច្នេះ? តើគាត់គិតទៅនៅជាមួយជនជាតិយូ
ដា ដែលខ្ចាត់ខ្ចាយក្នុងចំណោមជនជាតិក្រិក ហើយ
បង្រៀនពួកក្រិកឬ? ៣៦គាត់មានប្រសាសន៍ថា"អ្នក
រាល់គ្នានឹងតាមរកខ្ញុំ តែរកមិនឃើញទេ ដ្បិតអ្នករាល់
គ្នាពុំអាចទៅកន្លែងដែលខ្ញុំនៅនោះ បានឡើយ" តើ
មានន័យដូចម្ដេច?»។

## ទន្លេដែលមានទឹកផ្ដល់ជីវិត

៣៧នៅថ្ងៃបញ្ចប់ពិធីបុណ្យ ជាថ្ងៃឱឡារិកបំផុត
ព្រះយេស៊ូឈរនៅមុខបណ្ដាជន បន្លឺព្រះសូរសៀង
យ៉ាងខ្លាំងថា៖ «អ្នកណាស្រេកទឹក សុំអញ្ជើញមករក
ខ្ញុំ ហើយពិសាចុះ។ ៣៨អ្នកណាជឿលើខ្ញុំនឹងមានទន្លេ
បង្ហូរទឹកផ្ដល់ជីវិត ចេញពីអ្នកនោះមកដូចមានចែង
ទុកក្នុងគម្ពីរមកស្រាប់»។ ៣៩ព្រះអង្គមានព្រះបន្ទូល
ដូច្នេះ សំដៅទៅលើព្រះវិញ្ញាណដែលអស់អ្នកជឿ
លើព្រះអង្គនឹងត្រូវទទួល ដ្បិតពេលនោះ ព្រះជា
ម្ចាស់ពុំទាន់បាន ប្រទានព្រះវិញ្ញាណមកទេ ពីព្រោះ
ព្រះយេស៊ូពុំទាន់ សម្ដែងសិរីរុងរឿងនៅឡើយ។

## បណ្ដាជនខ្វែងគំនិតគ្នាអំពីព្រះយេស៊ូ

៤០ក្រោយពី បានឮព្រះបន្ទូលរបស់ព្រះអង្គ
ហើយ ក្នុងចំណោមបណ្ដាជន មានអ្នកខ្លះពោលថា៖
«លោកនេះពិតជាព្យាការី* ដែលយើងរង់ចាំនោះ
មែន!»។ ៤១អ្នកខ្លះទៀតពោលថា៖ «លោកនេះជា
ព្រះគ្រីស្ដ*»។ ប៉ុន្តែ មានអ្នកផ្សេងទៀតពោល
ជំទាស់ថា៖ «ព្រះគ្រីស្ដមិនមែនមកពីស្រុកកាលីឡេ
ទេ ៤២ដ្បិតមានចែងទុកក្នុងគម្ពីរថា "ព្រះគ្រីស្ដជាព្រះ
រាជវង្សរបស់ព្រះបាទដាវីឌ ហើយព្រះអង្គនឹងយាង
មកពីភូមិបេថ្លេហិម ជាភូមិកំណើតរបស់ព្រះបាទដាវី
ឌ"»។ ៤៣បណ្ដាជនក៏បាក់បែកគ្នា ព្រោះតែព្រះអ
ង្គ។ ៤៤ក្នុងចំណោមបណ្ដាជន មានអ្នកខ្លះចង់ចាប់
ព្រះអង្គ ប៉ុន្តែគ្មាននរណាហ៊ានចាប់ព្រះអង្គឡើយ។

## ពួកអ្នកធំមិនជឿលើព្រះអង្គ

៤៥កងរក្សាព្រះវិហារ* វិលទៅជួបពួកនាយក
បូជាចារ្យ* និងពួកខាងគណៈផារីស៊ី*វិញ លោក
ទាំងនោះសួរពួកគេថា៖ «ហេតុដូចម្ដេចបានជាអ្នក
រាល់គ្នាមិនចាប់គាត់នាំយកមក?»។ ៤៦កងរក្សាព្រះ
វិហារឆ្លើយថា៖ «ពុំដែលមាននរណានិយាយដូច
លោកនោះឡើយ»។ ៤៧ពួកខាងគណៈផារីស៊ីពោល
ទៅគេវិញថា៖ «អ្នករាល់គ្នាចាញ់បោកអ្នកនោះដែរ
ឬ! ៤៨ក្នុងចំណោមអ្នកដឹកនាំ និងក្នុងចំណោមពួក
ខាងគណៈផារីស៊ី គ្មាននរណាជឿលើអ្នកនោះសោះ
៤៩មានតែបណ្ដាជនដែលមិនស្គាល់ធម្មវិន័យទេ
ដែលជឿ។ ពួកនោះសុទ្ធតែត្រូវបណ្ដាសា!»។ ៥០
ក្នុងចំណោមពួកខាងគណៈផារីស៊ី មានបុរសម្នាក់
ឈ្មោះនីកូដេម ជាអ្នកដែលបានទៅគាល់ព្រះយេស៊ូ
កាលពីមុន មានប្រសាសន៍ថា៖ ៥១«តាមវិន័យរបស់
យើង យើងមិនអាចដាក់ទោសនរណាម្នាក់ បាន
ឡើយ ដរាបណាមិនទាន់បានឮពាក្យរបស់គេ ហើយ
មិនបានដឹងអំពីកិច្ចការ ដែលគេបានប្រព្រឹត្តសិនទេ
នោះ»។ ៥២ពួកគេតបទៅលោកវិញថា៖ «តើលោក
ជាពួកកាលីឡេដែរឬ? សុំលោកពិនិត្យពិច័យគម្ពីរមើ
ល៍ គ្មានព្យាការី*ណាម្នាក់កើតមកពីស្រុកកាលីឡេ
ឡើយ»។

[៥៣បន្ទាប់មក ម្នាក់ៗក៏វិលត្រឡប់ទៅផ្ទះរៀងៗ
ខ្លួនវិញ។

## ស្ត្រីម្នាក់ប្រព្រឹត្តសហាយស្មន់

១ព្រះយេស៊ូយាងទៅភ្នំដើមអូលីវ ២លុះព្រលឹម

ឡើង ព្រះអង្គវិលត្រឡប់ទៅព្រះវិហារជាថ្មីម្ដងទៀត
ប្រជាជនទាំងមូលនាំគ្នាមកគាល់ព្រះអង្គ ព្រះអង្គក៏
គង់បង្រៀនពួកគេ។ ៣ពេលនោះ ពួកធម្មាចារ្យ* និង
ពួកខាងគណៈផារីស៊ី*នាំស្ដ្រីម្នាក់ដែលគេទាន់ កំពុង
តែរួមសហាយស្មន់។ គេយកនាងនោះមកដាក់កណ្ដា
លចំណោមប្រជុំជន ៤ហើយទូលព្រះយេស៊ូថា៖«
លោកគ្រូ យើងចាប់ស្ដ្រីនេះបាន ក្នុងពេលកំពុងរួម
សហាយស្មន់។ ៥ក្នុងគម្ពីរលោកម៉ូសេបានបង្គាប់ឲ្យ
យើងយកដុំថ្ម គប់ស្ដ្រីប្រភេទនេះសម្លាប់ចោល។ ចុះ
លោកគ្រូវិញ តើលោកគ្រូគិតយ៉ាងណា?»។ ៦ពួកគេ
ទូលដូច្នេះដោយមានបំណងរកលេសចោទប្រកាន់
ព្រះអង្គ។ ប៉ុន្តែ ព្រះយេស៊ូឱនព្រះកាយចុះ ហើយ
យកព្រះអង្គុលីគូសវាសលើដី។ ៧ដោយពួកគេចេះតែ
សួរព្រះអង្គខ្លាំងពេក ព្រះអង្គងើបព្រះភ័ក្ត្រឡើង មាន
ព្រះបន្ទូលទៅគេថា៖ «ក្នុងចំណោមអ្នករាល់គ្នា សុំ
ឲ្យអ្នកដែលគ្មានបាបសោះ យកដុំថ្មគប់នាងមុនគេ
ទៅ!»។ ៨បន្ទាប់មកព្រះអង្គឈ្ងោកព្រះភ័ក្ត្រចុះ
ហើយគូសវាសលើដីសាជាថ្មី។ ៩ពួកគេបានឮព្រះ
បន្ទូលរបស់ព្រះអង្គដូច្នេះ ក៏នាំគ្នាដកខ្លួនថយម្នាក់ម្ដ
ងៗ ចាប់ផ្ដើមពីអ្នកមានវ័យចាស់ជាងគេទៅ នៅ
សល់តែព្រះយេស៊ូ និងស្ដ្រីនោះប៉ុណ្ណោះ។ ១០ពេល
នោះព្រះយេស៊ូងើបព្រះភ័ក្ត្រឡើង មានព្រះបន្ទូលទៅ
នាងថា៖ «នាងអើយ ពួកគេទៅណាអស់ហើយ គ្មាន
នរណាដាក់ទោសនាងទេឬ?»។ ១១នាងទូលព្រះអង្គ
ថា៖ «គ្មានទេ លោកម្ចាស់!»។ ព្រះយេស៊ូមានព្រះ
បន្ទូលទៅនាងថា៖ «ខ្ញុំក៏មិនដាក់ទោសនាងដែរ សុំ
អញ្ជើញទៅចុះ តែពីពេលនេះតទៅ កុំប្រព្រឹត្តអំពើ
បាបទៀតឡើយ»។]

## ព្រះយេស៊ូជាពន្លឺពិភពលោក

១២ព្រះយេស៊ូមានព្រះបន្ទូល ទៅកាន់បណ្ដាជន
សាជាថ្មីថា៖ «ខ្ញុំជាពន្លឺបំភ្លឺពិភពលោក អ្នកណាមក
តាមខ្ញុំ អ្នកនោះនឹងមិនដើរក្នុងសេចក្ដីងងឹតឡើយ គឺ
គេមានពន្លឺនាំគេទៅកាន់ជីវិត»។ ១៣ពួកខាងគណៈ
ផារីស៊ី*ទូលព្រះអង្គថា៖ «លោកធ្វើជាបន្ទាល់ឲ្យខ្លួន
លោកផ្ទាល់ សក្ខីភាពរបស់លោកមិនពិតទេ»។ ១៤
ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖ «ទោះបីខ្ញុំ
ធ្វើជាបន្ទាល់ឲ្យខ្លួនខ្ញុំផ្ទាល់ក៏ដោយ ក៏សក្ខីភាពរបស់
ខ្ញុំនៅតែពិតដែរ ដ្បិតខ្ញុំដឹងថា ខ្ញុំមកពីណា ហើយទៅ
ណាផង។ រីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នាពុំដឹងថា ខ្ញុំ
មកពីណា ហើយទៅណាឡើយ។ ១៥អ្នករាល់គ្នាវិនិច្ឆ័
យតាមរបៀបលោកីយ៍។ រីឯខ្ញុំវិញ ខ្ញុំមិនវិនិច្ឆ័យ
ទោសនរណាទេ ១៦ប្រសិនបើខ្ញុំវិនិច្ឆ័យទោស ការ
វិនិច្ឆ័យរបស់ខ្ញុំក៏ស្របតាមសេចក្ដីពិតដែរ ព្រោះខ្ញុំមិន
វិនិច្ឆ័យតែម្នាក់ខ្ញុំឡើយ គឺមានព្រះបិតាដែលបានចាត់
ខ្ញុំឲ្យមកវិនិច្ឆ័យជាមួយខ្ញុំ។ ១៧ក្នុងវិន័យរបស់អ្នករាល់
គ្នាមានចែងទុកមកថា បើមានពីរនាក់ធ្វើជាបន្ទាល់
ទើបសក្ខីភាពយកជាការបាន។ ១៨ខ្ញុំនេះហើយជា
បន្ទាល់សម្រាប់ខ្លួនខ្ញុំផ្ទាល់ ហើយព្រះបិតាដែលបាន
ចាត់ខ្ញុំ ឲ្យមកក៏ធ្វើជាបន្ទាល់ឲ្យខ្ញុំដែរ»។

១៩ពួកគេទូលសួរព្រះអង្គថា៖ «តើព្រះបិតា
របស់លោកនៅឯណា?»។ ព្រះយេស៊ូមានព្រះ
បន្ទូលតបទៅគេថា៖ «អ្នករាល់គ្នាមិនស្គាល់ខ្ញុំ ហើយ
ក៏មិនស្គាល់ព្រះបិតារបស់ខ្ញុំដែរ។ បើអ្នករាល់គ្នា
ស្គាល់ខ្ញុំ អ្នករាល់គ្នាមុខជាស្គាល់ព្រះបិតារបស់ខ្ញុំមិន
ខាន»។

២០ព្រះយេស៊ូមានព្រះបន្ទូលទាំងនេះ កាលព្រះ
អង្គបង្រៀនបណ្ដាជនក្នុងព្រះវិហារ* ត្រង់កន្លែងដាក់
ហិបប្រាក់តង្វាយ ប៉ុន្តែគ្មាននរណាចាប់ព្រះអង្គទេ
ព្រោះពេលកំណត់របស់ព្រះអង្គ មិនទាន់មកដល់នៅ
ឡើយ។

## ឋានៈរបស់បុត្រមនុស្ស

២១ព្រះយេស៊ូមានព្រះបន្ទូលទៅគេទៀត ថា៖
«ខ្ញុំនឹងចាកចេញទៅ ហើយអ្នករាល់គ្នានឹងតាមរកខ្ញុំ

តែអ្នករាល់គ្នានឹងត្រូវស្លាប់ ទាំងមានបាបជាប់ក្នុងខ្លួ
ន។ ទីណាខ្ញុំទៅ ទីនោះអ្នករាល់គ្នាពុំអាចនឹងទៅបាន
ឡើយ»។ ២២ជនជាតិយូដានិយាយគ្នាថា៖ «តើ
លោកនឹងសម្លាប់ខ្លួន ឬបានជាលោកពោលថា "ទី
ណាខ្ញុំទៅ ទីនោះអ្នករាល់គ្នាពុំអាចនឹងទៅបាន"
ដូច្នេះ?»។ ២៣ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «
អ្នករាល់គ្នាមានកំណើតនៅស្ថាននេះ រីឯខ្ញុំវិញខ្ញុំមាន
កំណើតមកពីស្ថានលើ។ អ្នករាល់គ្នាមានកំណើតពី
លោកីយ៍នេះ រីឯខ្ញុំវិញ ខ្ញុំពុំមែនមានកំណើតពី
លោកីយ៍នេះឡើយ។ ២៤ហេតុនេះហើយបានជាខ្ញុំ
ប្រាប់អ្នករាល់គ្នាថា អ្នករាល់គ្នានឹងត្រូវស្លាប់ទាំងមាន
បាបជាប់ក្នុងខ្លួន។ បើអ្នករាល់គ្នាមិនព្រមទទួល
ស្គាល់ឋានៈរបស់ខ្ញុំទេ អ្នករាល់គ្នានឹងត្រូវស្លាប់ ទាំង
មានបាបជាប់ក្នុងខ្លួនជាមិនខាន»។ ២៥គេទូលសួរ
ព្រះអង្គថា៖ «តើលោកមានឋានៈអ្វី?» ព្រះយេស៊ូ
មានព្រះបន្ទូលទៅគេថា៖ «ខ្ញុំបានប្រាប់អ្នករាល់គ្នា
តាំងពីដើមដំបូងមកម៉្លេះ។ ២៦ខ្ញុំមានសេចក្ដីជាច្រើន
ដែលត្រូវនិយាយអំពីអ្នករាល់គ្នា ព្រមទាំងវិនិច្ឆ័យ
ទោសអ្នករាល់គ្នាផង។ ប៉ុន្តែព្រះអង្គដែលបានចាត់ខ្ញុំ
ឲ្យមក ទ្រង់សម្តែងសេចក្ដីពិត ហើយអ្វីៗដែលខ្ញុំបាន
ឮពីព្រះអង្គ ខ្ញុំក៏យកមកថ្លែងប្រាប់មនុស្សលោកដែរ»
។ ២៧អ្នកទាំងនោះមិនយល់ថា ព្រះអង្គកំពុងតែមាន
ព្រះបន្ទូលអំពីព្រះបិតា ប្រាប់គេឡើយ។ ២៨ព្រះ
យេស៊ូមានព្រះបន្ទូលទៅគេទៀតថា៖ «កាលណា
អ្នករាល់គ្នាលើកបុត្រមនុស្សឡើង អ្នករាល់គ្នាមុខជា
នឹងស្គាល់ឋានៈរបស់ខ្ញុំពុំខាន ហើយអ្នករាល់គ្នានឹង
ដឹងថា ខ្ញុំមិនធ្វើការអ្វីមួយដោយសំអាងលើខ្លួនខ្ញុំ
ផ្ទាល់ឡើយ គឺខ្ញុំថ្លែងតែសេចក្ដីណាដែលព្រះបិតា
មានព្រះបន្ទូលប្រាប់មកខ្ញុំប៉ុណ្ណោះ។ ២៩ព្រះអង្គដែល
ចាត់ខ្ញុំឲ្យមក ទ្រង់គង់នៅជាមួយខ្ញុំ ព្រះអង្គមិនចោល
ខ្ញុំឲ្យនៅតែម្នាក់ឯងឡើយ ដ្បិតខ្ញុំតែងប្រព្រឹត្តកិច្ចការ
ណា ដែលគាប់ព្រះហឫទ័យព្រះអង្គជានិច្ច»។ ៣០
ពេលព្រះយេស៊ូមានព្រះបន្ទូលដូច្នេះ មានមនុស្សជា
ច្រើនជឿលើព្រះអង្គ។

## អ្នកជា និង អ្នកងារ

៣១ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលទៅ
កាន់ជនជាតិយូដាដែលបានជឿលើព្រះអង្គថា៖ «
ប្រសិនបើអ្នករាល់គ្នាស្ថិតនៅជាប់នឹងពាក្យរបស់ខ្ញុំ
អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំមែន។ ៣២អ្នករាល់គ្នា
នឹងស្គាល់សេចក្ដីពិត ហើយសេចក្ដីពិតនឹងរំដោះអ្នក
រាល់គ្នាឲ្យមានសេរីភាព»។ ៣៣គេនាំគ្នាទូលព្រះអង្គ
ថា៖ «យើងខ្ញុំជាកូនចៅលោកអប្រាហាំ! យើងខ្ញុំមិន
ដែលធ្វើខ្ញុំបម្រើអ្នកណាឡើយ ម្ដេចក៏លោកគ្រូថា
"អ្នករាល់គ្នានឹងមានសេរីភាព" ដូច្នេះ?»។ ៣៤ព្រះ
យេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នា
ដឹងច្បាស់ថា អ្នកណាប្រព្រឹត្តអំពើបាប អ្នកនោះជាខ្ញុំ
បម្រើរបស់អំពើបាប។ ៣៥ធម្មតា ខ្ញុំបម្រើមិនដែល
ស្ថិតនៅក្នុងផ្ទះរបស់ម្ចាស់ជាប់រហូតទេ មានតែកូន
របស់ម្ចាស់ប៉ុណ្ណោះ ដែលស្ថិតនៅក្នុងផ្ទះជាប់រហូតត
ទៅ។ ៣៦ប្រសិនបើព្រះបុត្រារំដោះអ្នករាល់គ្នា អ្នក
រាល់គ្នាពិតជាមានសេរីភាព។ ៣៧ខ្ញុំដឹងហើយថា អ្នក
រាល់គ្នាជាកូនចៅរបស់លោកអប្រាហាំ ក៏ប៉ុន្តែ អ្នក
រាល់គ្នារកសម្លាប់ខ្ញុំ ព្រោះពាក្យរបស់ខ្ញុំមិនស្ថិតនៅ
ក្នុងចិត្តអ្នករាល់គ្នាឡើយ។ ៣៨ខ្ញុំនិយាយតែអំពីអ្វីៗ
ដែលខ្ញុំបានឃើញនៅក្បែរព្រះបិតា រីឯអ្នករាល់គ្នាវិញ
អ្នករាល់គ្នាធ្វើតាមសេចក្ដីណាដែលអ្នករាល់គ្នាបាន
ឮពីឪពុករបស់អ្នករាល់គ្នា»។ ៣៩គេទូលព្រះអង្គថា៖
«ឪពុករបស់យើង គឺលោកអប្រាហាំ»។ ព្រះយេស៊ូ
មានព្រះបន្ទូលតបវិញថា៖ «បើអ្នករាល់គ្នា ពិតជា
កូនចៅលោកអប្រាហាំមែន អ្នករាល់គ្នាមុខជាធ្វើកិច្ច
ការ ដូចលោកអប្រាហាំធ្លាប់ធ្វើនោះមិនខាន ៤០តែ
ឥឡូវនេះ អ្នករាល់គ្នារកសម្លាប់ខ្ញុំ មកពីខ្ញុំនិយាយសេ
ចក្ដីពិត ដែលខ្ញុំបានឮពីព្រះជាម្ចាស់ លោកអប្រាហាំ
មិនបានប្រព្រឹត្តដូច្នេះទេ។ ៤១អ្នករាល់គ្នាធ្វើកិច្ចការ

ដែលឪពុកអ្នករាល់គ្នាប្រព្រឹត្ត»។ គេទូលព្រះអង្គថា៖ «យើងខ្ញុំជាកូនពេញច្បាប់ យើងមានឪពុកតែមួយគត់គឺព្រះជាម្ចាស់»។ ៤២ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ប្រសិនបើព្រះជាម្ចាស់ពិតជាឪពុកអ្នករាល់គ្នាមែន ម្ល៉េះសមអ្នករាល់គ្នាស្រឡាញ់ខ្ញុំពុំខាន ដ្បិតខ្ញុំចេញពីព្រះជាម្ចាស់មកទីនេះ។ ខ្ញុំមិនមែនមកដោយចិត្តឯងឡើយ គឺព្រះជាម្ចាស់បានចាត់ខ្ញុំឲ្យមក។ ៤៣ហេតុអ្វីបានជាអ្នករាល់គ្នាមិនយល់ពាក្យដែលខ្ញុំថ្លែងប្រាប់ដូច្នេះ? គឺមកពីអ្នករាល់គ្នាមិនអាចស្ដាប់ពាក្យរបស់ខ្ញុំបាន។ ៤៤អ្នករាល់គ្នាជាកូនចៅរបស់មារសាតាំង* ហើយអ្នករាល់គ្នាចង់ធ្វើ តាមចំណង់ចិត្តឪពុកអ្នករាល់គ្នា។ តាំងពីដើមរៀងមក វាបានសម្លាប់មនុស្ស ហើយមិនកាន់តាមសេចក្ដីពិតទេ ព្រោះគ្មានសេចក្ដីពិតនៅក្នុងខ្លួនវាសោះ។ ពេលវានិយាយកុហក នោះវានិយាយចេញពីគំនិតវាផ្ទាល់ ព្រោះវាជាមេកុហក ហើយជាឪពុកនៃអ្នកកុហក។ ៤៥រីឯខ្ញុំវិញ ខ្ញុំនិយាយសេចក្ដីពិតតែអ្នករាល់គ្នាមិនជឿខ្ញុំទេ។ ៤៦ក្នុងចំណោមអ្នករាល់គ្នា តើនរណាអាចចោទប្រកាន់ថា ខ្ញុំប្រព្រឹត្តអំពើបាបបាន? បើខ្ញុំនិយាយសេចក្ដីពិត ហេតុដូចម្ដេចបានជាអ្នករាល់គ្នាមិនជឿខ្ញុំ? ៤៧អ្នកណាកើតមកពីព្រះជាម្ចាស់ អ្នកនោះតែងស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គ។ រីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នាមិនមែនកើតមកពីព្រះជាម្ចាស់ទេ បានជាអ្នករាល់គ្នាមិនស្ដាប់ខ្ញុំដូច្នេះ»។

## ព្រះយេស៊ូ និង លោកអប្រាហាំ

៤៨ជនជាតិយូដាទូលព្រះអង្គថា៖ «យើងនិយាយថា លោកជាសាសន៍សាម៉ារី ហើយថាមានអារក្សចូលលោកនោះត្រូវមែន!»។ ៤៩ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «គ្មានអារក្សណាចូលខ្ញុំឡើយ តែខ្ញុំគោរពព្រះបិតារបស់ខ្ញុំហើយអ្នករាល់គ្នាបែរជាបន្ទុះបង្អាប់ខ្ញុំទៅវិញ។ ៥០ខ្ញុំមិនរកសិរីរុងរឿងសម្រាប់ខ្លួនខ្ញុំឡើយ គឺមានម្នាក់រកឲ្យខ្ញុំ ហើយវិនិច្ឆ័យទៀតផង។ ៥១ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាកាន់តាមពាក្យរបស់ខ្ញុំ អ្នកនោះនឹងមិនស្លាប់សោះឡើយ»។

៥២ជនជាតិយូដាទូលព្រះអង្គថា៖ «ឥឡូវនេះយើងដឹងច្បាស់ហើយថា លោកពិតជាមានអារក្សចូលមែន។ លោកអប្រាហាំនិងពួកព្យាការី*បានទទួលមរណភាពទៅហើយ រីឯលោកវិញលោកហ៊ានពោលថា អ្នកណាកាន់តាមពាក្យលោក អ្នកនោះមិនស្លាប់សោះឡើយ។ ៥៣តើលោកមានឋានៈធំជាងលោកអប្រាហាំ ជាបុព្វបុរសរបស់យើង ដែលទទួលមរណភាពទៅហើយនោះឬ? រីឯពួកព្យាការីក៏ទទួលមរណភាពទៅដែរ។ ចុះលោក លោកតាំងខ្លួនជាអ្វី?»។ ៥៤ព្រះយេស៊ូមានព្រះបន្ទូលថា៖ «បើខ្ញុំលើកតម្កើងខ្លួនខ្ញុំ សិរីរុងរឿងរបស់ខ្ញុំគ្មានតម្លៃអ្វីទាល់តែសោះ គឺព្រះបិតារបស់ខ្ញុំទេតើដែលលើកតម្កើងខ្ញុំ ព្រះអង្គនោះហើយដែលអ្នករាល់គ្នាថាជា "ព្រះរបស់យើង"។ ៥៥អ្នករាល់គ្នាមិនស្គាល់ព្រះអង្គទេ រីឯខ្ញុំ ខ្ញុំស្គាល់ព្រះអង្គប្រសិនបើខ្ញុំថា ខ្ញុំមិនស្គាល់ព្រះអង្គទេ ខ្ញុំមុខជានិយាយកុហកដូចអ្នករាល់គ្នាដែរ។ ប៉ុន្តែ ខ្ញុំស្គាល់ព្រះអង្គ ហើយកាន់តាមព្រះបន្ទូលរបស់ព្រះអង្គថែមទៀតផង។ ៥៦លោកអប្រាហាំជាឪពុករបស់អ្នករាល់គ្នាមានចិត្តត្រេកអរពន់ប្រមាណ ដោយសង្ឃឹមថានឹងឃើញខ្ញុំមកដល់។ លោកក៏បានឃើញមែន ហើយត្រេកអរសប្បាយ»។ ៥៧ជនជាតិយូដាពោលថា៖ «លោកមានអាយុមិនទាន់ទាំងបានហាសិបឆ្នាំផង ម្ដេចក៏ថាបានឃើញលោកអប្រាហាំដូច្នេះ?»។ ៥៨ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា មុនលោកអប្រាហាំកើតមក ខ្ញុំមានជីវិតរួចស្រេចទៅហើយ»។ ៥៩ពួកគេក៏រើសដុំថ្មបម្រុងនឹងគប់សម្លាប់ព្រះអង្គ ប៉ុន្តែ ព្រះយេស៊ូគៀសព្រះអង្គចេញពីព្រះវិហារ*បាត់ទៅ។

## ព្រះយេស៊ូប្រោស
## មនុស្សខ្វាក់ពីកំណើតម្នាក់ឲ្យបានជា

១ព្រះយេស៊ូយាងតាមផ្លូវ ទ្រង់ទតឃើញមនុស្ស
៩ម្នាក់ខ្វាក់តាំងពីកំណើត។ ២ពួកសាវ័កទូលសួរព្រះ
អង្គថា៖ «ព្រះគ្រូបុរសនេះកើតមកខ្វាក់ដូច្នេះ តើប
ណ្ដាលមកពីបាបរបស់នរណា?បាបរបស់គាត់ផ្ទាល់
ឬបាបរបស់ឪពុកម្ដាយគាត់?»។ ៣ព្រះយេស៊ូមាន
ព្រះបន្ទូលតបថា៖ «គាត់ខ្វាក់មិនមែនមកពីបាប
របស់ឪពុកម្ដាយគាត់ ឬបាបរបស់គាត់ទេ គាត់ខ្វាក់
ដូច្នេះ ដើម្បីឲ្យព្រះជាម្ចាស់បង្ហាញកិច្ចការរបស់ព្រះ
អង្គ នៅក្នុងគាត់។ ៤យើងត្រូវធ្វើកិច្ចការរបស់ព្រះអង្គ
ដែលបានចាត់ខ្ញុំឲ្យមកទាន់នៅភ្លឺនៅឡើយ ដ្បិតដល់
ពេលយប់ គ្មាននរណាអាចធ្វើការបានឡើយ។ ៥
ពេលខ្ញុំស្ថិតនៅក្នុងពិភពលោកនេះ ខ្ញុំជាពន្លឺបំភ្លឺពិភព
លោក»។ ៦កាលព្រះអង្គមានព្រះបន្ទូលដូច្នេះហើយ
ព្រះអង្គស្ដោះទឹកព្រះឱស្ឋទៅលើដី ធ្វើភក់លាបភ្នែក
មនុស្សខ្វាក់នោះ ៧រួចទ្រង់មានព្រះបន្ទូលទៅគាត់ថា
៖ «សុំអញ្ជើញទៅលុបមុខនៅស្រះស៊ីឡោមចុះ»
(ពាក្យ "ស៊ីឡោម" នេះមានន័យថាអ្នកដែលគេចាត់
ឲ្យទៅ)។ គាត់ក៏ចេញទៅលុបមុខពេលត្រឡប់មក
វិញ គាត់មើលឃើញ។៨អ្នកជិតខាងនិងអស់អ្នកដែល
ធ្លាប់ឃើញ គាត់សុំទាន កាលពីមុននាំគ្នាពោលថា៖
«បុរសនេះជាអ្នកដែលតែងអង្គុយសុំទានទេតើ!»។
៩អ្នកខ្លះពោលថា៖ «គាត់មែន!»។ ខ្លះទៀតថា៖ «
មិនមែនទេ អ្នកនេះមានមុខដូចគាត់!»។ រីឯបុរស
នោះវិញ គាត់ពោលថា៖ «គឺខ្ញុំហ្នឹងហើយ!»។ ១០គេ
ក៏នាំគ្នាសួរគាត់ថា៖ «ម្ដេចបានជាភ្នែកអ្នកភ្លឺ
ដូច្នេះ?»។ ១១គាត់ឆ្លើយថា៖ «មានលោកម្នាក់
ឈ្មោះយេស៊ូបានធ្វើភក់ យកមកលាបភ្នែកខ្ញុំ ហើយ
ប្រាប់ខ្ញុំថា "សុំអញ្ជើញទៅលុបមុខនៅស្រះស៊ីឡោម
ចុះ!" ខ្ញុំក៏ទៅលុបមុខហើយខ្ញុំមើលឃើញ»។ ១២គេ
សួរគាត់ថា៖ «លោកនោះនៅឯណា?»។ គាត់ឆ្លើយ
ថា៖ «ខ្ញុំមិនដឹងទេ!»។

## ពួកផារីស៊ីសួរចម្លើយអ្នកខ្វាក់ពីមុន

១៣គេនាំអ្នកដែលខ្វាក់ពីមុននោះ ទៅជួបពួក
ខាងគណៈផារីស៊ី*។ ១៤ថ្ងៃដែលព្រះយេស៊ូធ្វើភក់
និងប្រោសអ្នកខ្វាក់ឲ្យបានភ្លឺនោះ ជាថ្ងៃសប្ប័ទ១៥
ហេតុនេះហើយ បានជាពួកខាងគណៈផារីស៊ីនាំគ្នា
សួរម្ដងទៀត អំពីហេតុការណ៍ដែលធ្វើឲ្យភ្នែកគាត់
ភ្លឺ។ គាត់ឆ្លើយថា៖ «លោកបានយកភក់ដាក់ពីលើ
ភ្នែកខ្ញុំ ខ្ញុំទៅលុបមុខហើយក៏មើលឃើញ»។ ១៦ពួក
ខាងគណៈផារីស៊ីខ្លះពោលថា៖ «អ្នកនោះមិនមែន
មកពីព្រះជាម្ចាស់ទេ ដ្បិតគាត់ពុំគោរពវិន័យ*
សម្រាប់ថ្ងៃឈប់សម្រាក»។ ខ្លះទៀតពោលថា៖ «
តើមនុស្សបាបអាចធ្វើទីសម្គាល់ដូចម្ដេចបាន?» ពួក
គេក៏បាក់បែកគ្នា។ ១៧គេសួរអ្នកដែលខ្វាក់ពីមុននោះ
ម្ដងទៀតថា៖ «ចុះអ្នកវិញ តើអ្នកថា លោកដែលធ្វើ
ឲ្យអ្នកបានភ្លឺនោះជានរណា?»។ គាត់ឆ្លើយថា៖ «
លោកពិតជាព្យាការី*មែន!»។ ១៨ប៉ុន្តែជនជាតិយូដា
នៅតែមិនជឿថា កាលពីមុនបុរសនេះខ្វាក់ ហើយ
ឥឡូវបានមើលឃើញនោះឡើយ ទាល់តែហៅឪពុក
ម្ដាយគាត់មកសួរសិន។ ១៩គេសួរទៅឪពុកម្ដាយគាត់
ថា៖ «អ្នកនេះពិតជាកូនរបស់អ្នក ដែលអ្នកថាខ្វាក់ពី
កំណើតមែនឬ ចុះឥឡូវម្ដេចក៏ភ្នែកគាត់ភ្លឺ?»។ ២០
ឪពុកម្ដាយគាត់ឆ្លើយថា៖ «យើងខ្ញុំដឹងថាវាពិតជា
កូនរបស់យើងខ្ញុំមែន ហើយកើតមកខ្វាក់!។ ២១ត្រង់
ឯភ្នែកវាបានភ្លឺ ដោយហេតុយ៉ាងណាៗនោះ យើងខ្ញុំ
មិនដឹងទេ ហើយនរណាបានធ្វើឲ្យភ្នែកវាភ្លឺនោះ ក៏
យើងមិនដឹងដែរ!។ សូមអស់លោកសួរវាទៅ វាធំ
ហើយ វាឆ្លើយខ្លួនឯងបាន»។ ២២ឪពុកម្ដាយគាត់
និយាយដូច្នេះ មកពីខ្លាចជនជាតិយូដា ព្រោះជនជាតិ
យូដារួមគំនិតគ្នាបណ្ដេញអស់អ្នកដែលទទួលស្គាល់
ថា ព្រះយេស៊ូជាព្រះគ្រីស្ដ* ចេញពីធម្មសាលា*

របស់គេ។ ២៣ហេតុនេះហើយបានជាគាត់ពោលថា
"វាធំហើយ សូមសួរវាទៅ!"។

២៤ពួកខាងគណៈផារីស៊ី*បានហៅបុរស ដែល
ខ្វាក់ពីមុននោះ មកសួរជាលើកទីពីរ។ គេពោលទៅ
គាត់ថា៖ «ត្រូវនិយាយការពិតនៅចំពោះព្រះភ័ក្ត្រ
ព្រះជាម្ចាស់! យើងដឹងថាអ្នកនោះពិតជាមនុស្សបាប
មែន!»។ ២៥បុរសនោះតបថា៖ «លោកនោះជា
មនុស្សបាប ឬយ៉ាងណានោះ ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែ
ម៉្យាង គឺពីមុនខ្ញុំខ្វាក់ ឥឡូវនេះ ខ្ញុំមើលឃើញ»។ ២៦
ពួកគេសួរគាត់ថា៖ «តើអ្នកនោះបានធ្វើអ្វីដល់អ្នក?
គាត់បានធ្វើឲ្យភ្នែកអ្នកភ្លឺដោយវិធីណា?»។ ២៧គាត់
ឆ្លើយទៅគេវិញថា៖ «ខ្ញុំបានជម្រាបអស់លោករួច
មកហើយ តែអស់លោកពុំស្ដាប់ខ្ញុំទេ។ ហេតុដូចម្ដេច
បានជាអស់លោកចង់ឲ្យខ្ញុំនិយាយម្ដងទៀតដូច្នេះ?
ប្រហែលអស់លោកចង់ធ្វើជាសិស្ស របស់លោកនោះ
ដែរហើយមើលទៅ!»។ ២៨ពួកខាងគណៈផារីស៊ីក៏
ជេរប្រមាថគាត់ថា៖ «ឯងទេតើជាសិស្សរបស់គាត់!
រីឯយើងវិញ យើងជាសិស្សរបស់លោកម៉ូសេ!។ ២៩
យើងដឹងថាព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់
លោកម៉ូសេមែន។ រីឯអ្នកនោះវិញ យើងមិនដឹងថា
គាត់មកពីណាទេ!»។ ៣០បុរសនោះនិយាយតបទៅ
គេថា៖ «លោកនោះបានធ្វើឲ្យភ្នែកខ្ញុំភ្លឺ តែអស់
លោកមិនដឹងថា គាត់មកពីណា ដូច្នេះគួរឲ្យឆ្ងល់ណា
ស់។ ៣១យើងដឹងស្រាប់ហើយថា ព្រះជាម្ចាស់មិនស្ដា
ប់ពាក្យរបស់មនុស្សបាបទេ ព្រះអង្គស្ដាប់តែពាក្យ
របស់អ្នកគោរពប្រណិប័តន៍ព្រះអង្គនិងប្រព្រឹត្តតាម
ព្រះហឫទ័យព្រះអង្គ ប៉ុណ្ណោះ។ ៣២តាំងពីដើមរៀង
មក យើងមិនដែលឮថាមាននរណាធ្វើឲ្យភ្នែកមនុស្ស
ខ្វាក់ពីកំណើត បានភ្លឺនោះឡើយ។ ៣៣ប្រសិនបើ
លោកនោះមិនមកពីព្រះជាម្ចាស់ទេ លោកមិនអាច
ធ្វើការអ្វីបានទាល់តែសោះ»។ ៣៤ពួកគេនាំគ្នាពោល
ទៅគាត់ថា៖ «ឯងជាមនុស្សជាប់បាបពេញខ្លួន តាំង
ពីកំណើតមក ហើយឯងហ៊ានប្រដៅយើងទៀត!»។
គេក៏បណ្ដេញគាត់ចេញទៅខាងក្រៅ។

៣៥ព្រះយេស៊ូជ្រាបថា គេបានបណ្ដេញគាត់
កាលព្រះអង្គជួបគាត់ ទ្រង់មានព្រះបន្ទូលសួរថា៖ «
តើអ្នកជឿលើបុត្រមនុស្ស*ឬទេ?»។ ៣៦គាត់ទូល
ព្រះអង្គថា៖ «លោកម្ចាស់អើយ តើនរណាជាបុត្រ
មនុស្ស សូមប្រាប់ខ្ញុំឲ្យដឹងផង ដើម្បីឲ្យខ្ញុំជឿលើព្រះ
អង្គ»។ ៣៧ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «
អ្នកឃើញលោកស្រាប់ គឺអ្នកដែលកំពុងតែនិយាយ
ជាមួយអ្នកហ្នឹងហើយជាបុត្រមនុស្ស»។ ៣៨គាត់ទូល
ព្រះយេស៊ូថា៖ «បពិត្រព្រះអម្ចាស់!ទូលបង្គំជឿលើ
ព្រះអង្គហើយ»។ គាត់ក៏ក្រាបថ្វាយបង្គំព្រះអង្គ។

៣៩បន្ទាប់មកព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំ
មកក្នុងពិភពលោកនេះ ដើម្បីវិនិច្ឆ័យចិត្តមនុស្សគឺឲ្យ
មនុស្សខ្វាក់មើលឃើញ ហើយឲ្យមនុស្សមើលឃើញ
ត្រឡប់ទៅជាខ្វាក់វិញ»។ ៤០ពួកខាងគណៈផារីស៊ី
ខ្លះ ដែលនៅទីនោះជាមួយព្រះអង្គបានឮដូច្នេះ ក៏
ទូលព្រះអង្គថា៖ «ប្រហែលជាលោកចង់ថា យើងខ្ញុំ
នេះជាមនុស្សខ្វាក់ដែរហើយមើលទៅ!»។ ៤១ព្រះ
យេស៊ូមានព្រះបន្ទូលឆ្លើយទៅគេវិញថា៖ «ប្រសិន
បើអ្នករាល់គ្នាខ្វាក់មែន អ្នករាល់គ្នាគ្មានបាបទេ។
ផ្ទុយទៅវិញ មកពីអ្នករាល់គ្នាថាខ្លួនមើលឃើញដូច្នេះ
ហើយ បានជាអ្នករាល់គ្នានៅតែជាប់បាបរហូត»។

## ព្រះយេស៊ូជាអ្នកគង្វាលដ៏ល្អ

១«ខ្ញុំសុំប្រាប់ ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នក
១០ណាមិនចូលក្នុងក្រោលចៀមតាមទ្វារតែផ្លោះ
ចូលតាមកន្លែងផ្សេងអ្នកនោះជាចោរលួចចោរប្លន់។
២រីឯអ្នកដែលចូលតាមទ្វារ ពិតជាអ្នកគង្វាលរបស់ចៀ
ម។ ៣ឆ្មាំទ្វារបើកទ្វារឲ្យគាត់ចូល ហើយចៀមទាំង
ប៉ុន្មានស្ដាប់សំឡេងគាត់។ គាត់ហៅចៀមផ្ទាល់របស់
គាត់តាមឈ្មោះរបស់វារៀងៗខ្លួន រួចនាំចេញទៅខាង

ក្រៅ។ ៤លុះគាត់បញ្ចេញចៀមចេញពីក្រោលអស់
ហើយគាត់ដើរនាំមុខវា ហើយវាដើរតាមក្រោយគាត់
ពីព្រោះវាស្គាល់សំឡេងរបស់គាត់។ ៥ចៀមទាំងនោះ
មិនដើរតាមអ្នកដទៃ ជាដាច់ខាត ផ្ទុយទៅវិញ វារត់
គេចចេញឆ្ងាយពីគេ ព្រោះវាមិនស្គាល់សំឡេងរបស់
អ្នកដទៃឡើយ»។
៦ព្រះយេស៊ូមានព្រះបន្ទូល ជាប្រស្នានេះឲ្យគេ
ស្ដាប់ ប៉ុន្តែគេពុំបានយល់ថាព្រះអង្គមានព្រះបន្ទូល
អំពីរឿងអ្វីឡើយ។

៧ព្រះយេស៊ូមានព្រះបន្ទូលទៅគេ ទៀតថា៖ «
ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ខ្ញុំហ្នឹងហើយជា
ទ្វារសម្រាប់ឲ្យចៀមចេញចូល។ ៨អ្នកដែលមកមុនខ្ញុំ
ទាំងប៉ុន្មាន សុទ្ធតែជាចោរលួចចោរប្លន់ទាំងអស់
ចៀមមិនបានស្ដាប់សំឡេង អ្នកទាំងនោះឡើយ។ ៩
ខ្ញុំហ្នឹងហើយជាទ្វារ អ្នកណាចូលតាមខ្ញុំ ព្រះជាម្ចាស់
នឹងសង្គ្រោះអ្នកនោះ អ្នកនោះនឹងចេញចូល ព្រម
ទាំងរកឃើញចំណីអាហារ[ង]ថែមទៀតផង។ ១០ចោរវា
មកគិតតែពីលួចប្លន់គិតតែពីសម្លាប់ និងបំផ្លាញ
ប៉ុណ្ណោះ។ រីឯខ្ញុំវិញ ខ្ញុំមកដើម្បីឲ្យមនុស្សលោកមាន
ជីវិត ហើយឲ្យគេមានជីវិតពេញបរិបូណ៌។

១១ខ្ញុំហ្នឹងហើយជាអ្នកគង្វាលដ៏ល្អ អ្នកគង្វាលដ៏
ល្អតែងតែស៊ូប្ដូរជីវិត ដើម្បីចៀមរបស់ខ្លួន។ ១២រីឯអ្នក
ស៊ីឈ្នួលវិញ កាលគេឃើញចចកមកដល់ គេរត់
ចោលចៀម ទុកឲ្យចចកខាំអូសយកទៅ ហើយដេញ
កំចាត់កំចាយជាមិនខាន ពីព្រោះអ្នកនោះមិនមែនជា
អ្នកគង្វាល ហើយក៏មិនមែនជាម្ចាស់របស់ចៀមផង។
១៣អ្នកនោះមិនខ្វល់ខ្វាយនឹងចៀមឡើយ ព្រោះគេ
គ្រាន់តែស៊ីឈ្នួលប៉ុណ្ណោះ។ ខ្ញុំហ្នឹងហើយជាអ្នក
គង្វាលដ៏ល្អ។ ១៤ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ចៀមរបស់ខ្ញុំ
ក៏ស្គាល់ខ្ញុំ ១៥គឺដូចព្រះបិតាស្គាល់ខ្ញុំ ហើយខ្ញុំស្គាល់
ព្រះបិតាដូច្នោះដែរ។ ខ្ញុំស៊ូប្ដូរជីវិតដើម្បីចៀមរបស់
ខ្ញុំ។ ១៦ខ្ញុំមានចៀមឯទៀតៗ ដែលមិននៅក្នុងក្រោល
នេះទេ។ ខ្ញុំត្រូវតែនាំចៀមទាំងនោះមកដែរ។ ចៀម
ទាំងនោះនឹងស្ដាប់សំឡេងខ្ញុំ ហើយនៅពេលនោះ
នឹងមានហ្វូងចៀមតែមួយ មានអ្នកគង្វាលតែមួយ។
១៧ព្រះបិតាស្រឡាញ់ខ្ញុំ ព្រោះខ្ញុំសុខចិត្តស៊ូប្ដូរជីវិត
ដើម្បីឲ្យបានជីវិតនោះមកវិញ។ ១៨គ្មាននរណាដក
ហូតជីវិតរបស់ខ្ញុំបានឡើយ គឺខ្ញុំស៊ូប្ដូរជីវិតដោយខ្លួន
ខ្ញុំផ្ទាល់តែម្ដង។ ខ្ញុំមានអំណាចនឹងស៊ូប្ដូរជីវិតរបស់ខ្ញុំ
ហើយខ្ញុំក៏មានអំណាចនឹងយកជីវិតនោះមកវិញ តាម
ព្រះបញ្ជាដែលខ្ញុំបានទទួលពីព្រះបិតាមក»។

១៩ព្រះបន្ទូលទាំងនេះ ធ្វើឲ្យជនជាតិយូដាបាក់
បែកគ្នាម្ដងទៀត។ ២០មានគ្នាគេជាច្រើនពោលថា៖
«អ្នកនោះមានអារក្សចូល! គាត់វង្វេងស្មារតីហើយ!
ស្ដាប់គាត់ធ្វើអ្វី?»។ ២១អ្នកខ្លះទៀតពោលថា៖ «
ពាក្យទាំងនេះមិនមែនជាពាក្យរបស់មនុស្ស ដែល
មានអារក្សចូលទេ! តើអារក្សអាចធ្វើឲ្យភ្នែកមនុស្ស
ខ្វាក់ភ្លឺកើតឬ?»។

## ជនជាតិយូដាមិនទទួលស្គាល់ព្រះយេស៊ូ

២២ពេលនោះជារដូវរងា គេនាំគ្នាធ្វើបុណ្យរំលឹក
ពិធីឆ្លងព្រះវិហារ* នៅក្រុងយេរូសាឡឹម។ ២៣ព្រះ
យេស៊ូយាងចុះឡើង ក្នុងថែវព្រះវិហារដែលមាន
ឈ្មោះថា «ថែវព្រះបាទសាឡូម៉ូន»។ ២៤ជនជាតិយូ
ដានាំគ្នាចោមរោមព្រះអង្គ ទូលសួរថា៖ «តើលោក
ទុកឲ្យយើងខ្ញុំនៅរារែកក្នុងចិត្ត ដល់ណាទៀត?
ប្រសិនបើលោកពិតជាព្រះគ្រីស្ដ*មែន សូមប្រាប់
យើងខ្ញុំឲ្យត្រង់ៗមក»។ ២៥ព្រះយេស៊ូមានព្រះបន្ទូល
តបទៅគេថា៖ «ខ្ញុំបានប្រាប់អ្នករាល់គ្នារួចមកហើយ
តែអ្នករាល់គ្នាមិនជឿទេ។ កិច្ចការទាំងប៉ុន្មាន ដែលខ្ញុំ
បានធ្វើក្នុងព្រះនាមព្រះបិតារបស់ខ្ញុំ ជាសក្ខីភាព*
បញ្ជាក់អំពីខ្ញុំស្រាប់។ ២៦ប៉ុន្តែអ្នករាល់គ្នាមិនជឿសោះ
ព្រោះអ្នករាល់គ្នាមិននៅក្នុងចំណោមចៀមរបស់ខ្ញុំ។
២៧ចៀមរបស់ខ្ញុំតែងស្ដាប់សំឡេងខ្ញុំ ខ្ញុំស្គាល់ចៀម

ទាំងនោះហើយចៀមទាំងនោះមកតាមខ្ញុំ។ ២៨ខ្ញុំឲ្យ
គេមានជីវិតអស់កល្បជានិច្ច គេមិនវិនាសអន្តរាយ
ឡើយ ហើយគ្មាននរណាអាចឆក់យកគេពីដៃខ្ញុំ ជា
ដាច់ខាត។ ២៩ព្រះបិតាដែលបានប្រទានចៀមទាំង
នោះមកឲ្យខ្ញុំ ទ្រង់មានអំណាចធំលើសអ្វីៗទាំងអស់
គ្មាននរណាអាចឆក់យកគេពីព្រះហស្តព្រះបិតាបាន
ឡើយ។ ៣០ខ្ញុំនិងព្រះបិតាជាអង្គតែមួយ»។ ៣១ជន
ជាតិយូដានាំគ្នារើសដុំថ្មម្តងទៀតបម្រុងនឹងគប់
សម្លាប់ព្រះអង្គ។ ៣២ព្រះយេស៊ូមានព្រះបន្ទូលទៅគេ
ថា៖ «ខ្ញុំបានបង្ហាញឲ្យអ្នករាល់គ្នាឃើញកិច្ចការដ៏ល្អ
ប្រសើរជាច្រើន ដែលព្រះបិតាប្រទានឲ្យខ្ញុំធ្វើ។ ក្នុងប
ណ្តាកិច្ចការទាំងនោះ តើកិច្ចការណាមួយ ដែលនាំឲ្យ
អ្នករាល់គ្នាយកដុំថ្មបម្រុងនឹងគប់សម្លាប់ខ្ញុំ?»។ ៣៣
ជនជាតិយូដាតបទៅព្រះអង្គថា៖ «យើងចង់សម្លាប់
លោកមិនមែនមកពី លោកបានធ្វើកិច្ចការដ៏ល្អ
ប្រសើរណាមួយនោះឡើយ គឺមកពីលោកបានពោល
ពាក្យ ប្រមាថព្រះជាម្ចាស់ ដ្បិតលោកជាមនុស្ស
ហើយតាំងខ្លួនជាព្រះជាម្ចាស់»។ ៣៤ព្រះយេស៊ូមាន
ព្រះបន្ទូលថា៖ «ក្នុងធម្មវិន័យ*របស់អ្នករាល់គ្នា
មានចែងទុកមកថា ព្រះជាម្ចាស់មានព្រះបន្ទូលថា
អ្នករាល់គ្នាជាព្រះ។ ៣៥យើងមិនអាចលុបបំបាត់គម្ពីរ
បានឡើយ បើគម្ពីរហៅអស់អ្នកដែលទទួលព្រះ
បន្ទូលថាជា ព្រះ"ដូច្នេះ ៣៦ចុះហេតុដូចម្តេចបានជា
ពេលខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំជាបុត្រារបស់ព្រះជា
ម្ចាស់ អ្នករាល់គ្នាបែរជាពោលថាខ្ញុំប្រមាថព្រះអង្គ
ទៅវិញ? ព្រះបិតាបានប្រោសខ្ញុំឲ្យវិសុទ្ធ ហើយចាត់
ខ្ញុំ ឲ្យមកក្នុងពិភពលោកនេះ ទៀតផង។ ៣៧ប្រសិន
បើ ខ្ញុំមិនធ្វើការរបស់ព្រះបិតាទេនោះ សុំកុំជឿខ្ញុំឡើ
យ។ ៣៨ប៉ុន្តែបើខ្ញុំធ្វើកិច្ចការរបស់ព្រះអង្គ ទោះបីអ្នក
រាល់គ្នាមិនជឿខ្ញុំក៏ដោយ ក៏សុំជឿទៅលើកិច្ចការទាំង
នោះចុះ ដើម្បីឲ្យបានដឹងហើយរឹតតែដឹងទៀតថា
ព្រះបិតាស្ថិតនៅក្នុងខ្ញុំ ខ្ញុំស្ថិតនៅក្នុងព្រះបិតា»។

៣៩គេរកចាប់ព្រះយេស៊ូម្តងទៀត ប៉ុន្តែព្រះអង្គ
គេចផុតពីគេទៅ។

៤០ព្រះយេស៊ូយាង ទៅត្រើយខាងនាយទន្លេយ័រ
ដាន់ជាថ្មីម្តងទៀត ត្រង់កន្លែងដែលលោកយ៉ូហាន
ធ្លាប់ជ្រមុជទឹក*ឲ្យបណ្តាជន កាលពីមុនរួចព្រះអង្គ
គង់នៅទីនោះ។ ៤១មានមនុស្សជាច្រើននាំគ្នាមក
គាល់ព្រះអង្គ គេពោលថា៖ «លោកយ៉ូហានពុំបាន
ធ្វើទីសម្គាល់ណាមួយឡើយ ប៉ុន្តែពាក្យទាំងប៉ុន្មាន
ដែលគាត់និយាយអំពីលោកនេះសុទ្ធតែត្រូវទាំង
អស់»។ ៤២មនុស្សជាច្រើននៅទីនោះបានជឿលើ
ព្រះយេស៊ូ។

## លោកឡាសារទទួលមរណភាព

១១ ១នៅភូមិបេតថានី មានបុរសម្នាក់ឈ្មោះ
ឡាសារ គាត់មានជំងឺ។ នាងម៉ាថានិងនាងម៉ារីជាបង
ស្រីរបស់គាត់ ក៏រស់នៅក្នុងភូមិនោះដែរ។ ២នាងម៉ារី
នេះ ជាស្ត្រីម្នាក់ដែលបានចាក់ប្រេងក្រអូបលើព្រះ
បាទារបស់ព្រះអម្ចាស់ ព្រមទាំងបានយកសក់របស់
នាងមកជូតផង។ រីឯលោកឡាសារដែលឈឺនោះ
ត្រូវជាប្អូនបង្កើតរបស់នាង។ ៣នាងទាំងពីរនាក់បាន
ចាត់គេឲ្យទៅទូលព្រះយេស៊ូថា៖ «លោកម្ចាស់អ្នក
ដែលលោកស្រឡាញ់ កំពុងតែមានជំងឺ»។ ៤កាល
ព្រះយេស៊ូជ្រាបដំណឹងនេះ ព្រះអង្គមានព្រះបន្ទូលថា
៖ «ជំងឺនេះកើតឡើង មិនមែនឲ្យគាត់បាត់បង់ជីវិត
ទេ គឺដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់
ព្រមទាំងឲ្យព្រះបុត្រារបស់ព្រះអង្គសម្តែងសិរីរុងរឿង
វិញ»។

៥ព្រះយេស៊ូស្រឡាញ់នាងម៉ាថា ប្អូនស្រីរបស់
នាងនិងលោកឡាសារណាស់។ ៦កាលព្រះអង្គជ្រាប
ដំណឹងថា លោកឡាសារមានជំងឺ ព្រះអង្គគង់នៅ
កន្លែងដដែលនោះពីរថ្ងៃទៀត ៧បន្ទាប់មក ព្រះអង្គ
មានព្រះបន្ទូលទៅពួកសាវ័ក*ថា៖ «យើងនាំគ្នាត្រ

ឡប់ទៅស្រុកយូដាវិញ»។ ៨ពួកសាវ័កទូលព្រះអង្គ
ថា៖ «ព្រះគ្រូ ជនជាតិយូដាទើបនឹងចង់យកដុំថ្មគប់
ធ្វើគុតព្រះអង្គថ្មីៗនេះសោះ ហេតុដូចម្ដេចបានជា
ព្រះអង្គចង់វិលទៅស្រុកនោះវិញ!»។ ៩ព្រះយេស៊ូ
មានព្រះបន្ទូលតបថា៖ «ក្នុងមួយថ្ងៃមានដប់ពីរម៉ោង
អ្នកណាដើរនៅពេលថ្ងៃអ្នកនោះមិនជំពប់ជើងដួល
ឡើយ ព្រោះគេឃើញពន្លឺរបស់ពិភពលោកនេះ។ ១០
ផ្ទុយទៅវិញអ្នកណាដើរនៅពេលយប់ អ្នកនោះមុខតែ
ជំពប់ជើងដួលជាមិនខាន ព្រោះគេគ្មានពន្លឺនៅក្នុង
ខ្លួនទេ»។ ១១ក្រោយមក ព្រះអង្គមានព្រះបន្ទូលទៅ
គេថែមទៀតថា៖ «ឡាសារជាមិត្តសំឡាញ់របស់
យើងសំរាន្តលក់ទៅហើយខ្ញុំត្រូវតែទៅដាស់គាត់ឲ្យ
ភ្ញាក់ឡើងវិញ»។ ១២ពួកសាវ័កទូលព្រះអង្គថា៖«
បពិត្រព្រះអម្ចាស់ ប្រសិនបើគាត់សំរាន្តលក់ដូច្នេះ
គាត់នឹងបានជាវិញមិនខាន»។ ១៣តាមពិតព្រះ
យេស៊ូចង់មានព្រះបន្ទូលថា លោកឡាសារស្លាប់បាត់
ទៅហើយ ប៉ុន្តែពួកសាវ័កស្មានថាព្រះអង្គមានព្រះ
បន្ទូលថា គាត់សំរាន្តលក់ធម្មតា។ ១៤ហេតុនេះហើយ
បានជាព្រះអង្គមានព្រះបន្ទូលបញ្ជាក់ យ៉ាងច្បាស់ថា
៖ «ឡាសារស្លាប់ទៅហើយ ១៥បើគិតពីប្រយោជន៍
អ្នករាល់គ្នា ខ្ញុំសប្បាយចិត្តដោយខ្ញុំមិនបាននៅទីនោះ
ដើម្បីឲ្យអ្នករាល់គ្នាបានជឿ។ឥឡូវនេះយើងនាំគ្នា
ទៅផ្ទះគាត់»។ ១៦ពេលនោះសាវ័កថូម៉ាស់ហៅឌីឌីម
ពោលទៅសាវ័កឯទៀតថា៖ «មក!យើងនាំគ្នាទៅរួម
ស្លាប់ជាមួយព្រះអង្គដែរ!»។

## ព្រះយេស៊ូជាអ្នកផ្ដល់ជីវិតរស់ឡើងវិញ

១៧កាលព្រះយេស៊ូយាងទៅដល់ ព្រះអង្គក៏
ជ្រាបថា គេបានដាក់សពលោកឡាសារក្នុងផ្នូរបួនថ្ងៃ
ហើយ។ ១៨ភូមិបេថានីមានចម្ងាយប្រមាណបីគីឡូ
ម៉ែត្រពីក្រុងយេរូសាឡឹម។ ១៩មានជនជាតិយូដាជា
ច្រើន នាំគ្នាមកជួយរំលែកទុក្ខនាងម៉ាថានិង នាងម៉ារី
ក្នុងពេលប្អូនស្លាប់។

២០កាលនាងម៉ាថាបានដឹងថា ព្រះយេស៊ូយាង
មកដល់នាងក៏ចេញទៅទទួលព្រះអង្គ រីឯនាងម៉ារីវិញ
នាងអង្គុយនៅក្នុងផ្ទះ។ ២១នាងម៉ាថាទូលព្រះយេស៊ូ
ថា៖ «លោកម្ចាស់ប្រសិនបើលោកបាននៅទីនេះប្អូន
នាងខ្ញុំមិនស្លាប់ទេ។ ២២ប៉ុន្តែឥឡូវនេះ នាងខ្ញុំដឹងថា
បើលោកសុំអ្វីពីព្រះជាម្ចាស់ក៏ដោយ ព្រះអង្គមុខជា
នឹងប្រទានឲ្យមិនខាន»។ ២៣ព្រះយេស៊ូមានព្រះ
បន្ទូលទៅនាងថា៖ «ប្អូននាងនឹងរស់ឡើងវិញ»។
២៤នាងទូលទៅព្រះអង្គវិញថា៖ «នាងខ្ញុំដឹងហើយ
នៅថ្ងៃចុងក្រោយបំផុត កាលណាមនុស្សស្លាប់នឹង
រស់ឡើងវិញ ប្អូននាងខ្ញុំ ក៏នឹងរស់ឡើងវិញដែរ»។
២៥ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំហ្នឹង
ហើយដែលប្រោសមនុស្សឲ្យរស់ឡើងវិញ ខ្ញុំនឹងផ្ដល់
ឲ្យគេមានជីវិត។ អ្នកណាជឿលើខ្ញុំទោះបីស្លាប់ទៅ
ហើយក៏ដោយក៏នឹងបានរស់ជាមិនខាន។ ២៦រីឯអស់
អ្នកដែលកំពុងតែមានជីវិត នៅរស់ហើយជឿលើខ្ញុំ
មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ?»
។ ២៧នាងម៉ាថាទូលព្រះអង្គថា៖ «បពិត្រព្រះ
អម្ចាស់! ខ្ញុំម្ចាស់ជឿថា ព្រះអង្គពិតជាព្រះគ្រីស្ដ* ជា
ព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយពិតជាព្រះអង្គ
ដែលត្រូវយាងមកក្នុងពិភពលោកនេះមែន!»។

## ព្រះយេស៊ូទ្រង់ព្រះកន្សែង

២៨នាងម៉ាថានិយាយដូច្នេះហើយ ក៏ចេញទៅ
ហៅនាងម៉ារីជាប្អូនដោយស្ងាត់ៗថា៖ «ព្រះគ្រូយាង
មកដល់ហើយ ព្រះអង្គហៅប្អូនឯង»។ ២៩នាងម៉ារីឮ
ហើយ ក៏ស្ទុះក្រោកឡើងទៅគាល់ព្រះយេស៊ូជា
ប្រញាប់។ ៣០ពេលនោះព្រះអង្គពុំទាន់យាងចូលក្នុង
ភូមិនៅឡើយទេ គឺព្រះអង្គគង់នៅកន្លែងដែលនាងម៉ា
ថាទៅជួប។ ៣១ជនជាតិយូដាដែលមកជួយរំលែកទុក្ខ
ក្នុងផ្ទះជាមួយនាងម៉ារី ឃើញនាងស្ទុះក្រោកឡើង
ប្រញាប់ប្រញាល់ចេញទៅខាងក្រៅដូច្នេះ ក៏នាំគ្នា
ចេញទៅតាម ព្រោះគេស្មានថានាងទៅយំឯផ្នូរ។ ៣២

លុះនាងម៉ារី ទៅដល់កន្លែងព្រះយេស៊ូគង់នៅហើយ នាងឃើញព្រះអង្គ ក៏ក្រាបទៀបព្រះបាទាទូលថា៖ «លោកម្ចាស់! ប្រសិនបើលោកបាននៅទីនេះ ប្អូនប្រុសនាងខ្ញុំមិនស្លាប់ទេ»។ ៣៣ពេលព្រះយេស៊ូឃើញនាងម៉ារី និងជនជាតិយូដាដែលមកជាមួយនាងយំដូច្នេះ ព្រះអង្គរំជួលព្រះហឫទ័យ ហើយរន្ធត់ជាខ្លាំងផង។ ៣៤ព្រះអង្គមានព្រះបន្ទូលសួរថា៖ «តើអ្នករាល់គ្នាយកសពទៅទុក នៅឯណា?»។ គេទូលព្រះអង្គថា៖ «សូមអញ្ជើញមកលោកនឹងឃើញ»។ ៣៥ពេលនោះព្រះយេស៊ូទ្រង់ព្រះកន្សែង។ ៣៦ជនជាតិយូដានាំគ្នាពោលថា៖ «មើល៍! លោកស្រឡាញ់ឡាសារខ្លាំងណាស់!»។ ៣៧ ប៉ុន្តែនៅក្នុងចំណោមពួកគេមានអ្នកខ្លះនិយាយថា៖ «លោកអាចធ្វើឲ្យមនុស្សខ្វាក់មើលឃើញ ម្ដេចក៏លោកមិនធ្វើឲ្យឡាសារគេចផុតពីស្លាប់ផងទៅ!»។

## ព្រះយេស៊ូប្រោសឡាសារឲ្យបានរស់ឡើងវិញ

៣៨ព្រះយេស៊ូរំជួលព្រះហឫទ័យម្ដងទៀត រួចយាងទៅផ្នូរ។ ផ្នូរនោះជារូងភ្នំមានថ្មបាំងនៅមាត់រូង។ ៣៩ព្រះយេស៊ូមានព្រះបន្ទូលថា៖ «សុំយកថ្មនេះចេញ!»។ នាងម៉ាថាជាបងរបស់សពទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់សពធំក្លិនហើយ ព្រោះគេបានយកមកដាក់ តាំងពីបួនថ្ងៃម្ល៉េះ»។ ៤០ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំបានប្រាប់នាងរួចមកហើយថា បើនាងជឿនាងនឹងឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់»។ ៤១គេក៏យកថ្មចេញពីមាត់ផ្នូរ។ ព្រះយេស៊ូងើបព្រះភ័ក្ត្រទតទៅលើ មានព្រះបន្ទូលថា៖ «បពិត្រព្រះបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គដែលទ្រង់ព្រះសណ្ដាប់ទូលបង្គំ។ ៤២ចំពោះទូលបង្គំទូលបង្គំដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់ទូលបង្គំជានិច្ច ប៉ុន្តែទូលបង្គំទូលព្រះអង្គដូច្នេះ ដើម្បីឲ្យបណ្ដាជនដែលនៅជុំវិញទូលបង្គំជឿថា ព្រះអង្គពិតជាបានចាត់ទូលបង្គំឲ្យមកមែន»។ ៤៣លុះព្រះអង្គមានព្រះបន្ទូលដូច្នេះហើយ ទ្រង់បន្លឺព្រះសូរសៀងខ្លាំងៗថា៖ «ឡាសារអើយ! ចេញមក!»។ ៤៤ពេលនោះលោកឡាសារដែលបានស្លាប់ ក៏ចេញពីផ្នូរមក មានទាំងក្រណាត់រុំដៃជើងនិងកន្សែងគ្របមុខផង។ ព្រះយេស៊ូមានព្រះបន្ទូលទៅពួកគេថា៖ «សុំស្រាយក្រណាត់ចេញពីគាត់ ហើយឲ្យគាត់ទៅចុះ»។

## ការឃុបឃិតចាប់ព្រះយេស៊ូ

៤៥ជនជាតិយូដាជាច្រើននាក់ ដែលមកផ្ទះនាងម៉ារីបានឃើញព្រះយេស៊ូធ្វើកិច្ចការទាំងនោះ ក៏ជឿលើព្រះអង្គ។ ៤៦ប៉ុន្តែមានគ្នាគេខ្លះទៅជួបពួកខាងគណៈផារីស៊ី* រៀបរាប់នូវកិច្ចការដែលព្រះយេស៊ូបានធ្វើ។ ៤៧ពេលនោះពួកនាយកបូជាចារ្យ* និងពួកខាងគណៈផារីស៊ី បានកោះហៅក្រុមប្រឹក្សាជាន់ខ្ពស់* មកប្រជុំហើយពោលថា៖ «អ្នកនោះបានធ្វើទីសម្គាល់ជាច្រើន តើយើងគិតធ្វើដូចម្ដេច?។ ៤៨ប្រសិនបើយើងបណ្ដោយឲ្យគាត់ធ្វើដូច្នេះតទៅទៀត ប្រជាជនមុខតែជឿទៅលើគាត់ទាំងអស់គ្នា ហើយជនជាតិរ៉ូម៉ាំងនឹងមកបំផ្លាញព្រះវិហារ* និងបំបាត់ជាតិសាសន៍របស់យើងជាមិនខាន»។ ៤៩នៅក្នុងចំណោមពួកគេមានលោកម្នាក់ឈ្មោះកៃផាសដែលជាមហាបូជាចារ្យ នៅឆ្នាំនោះលោកមានប្រសាសន៍ទៅគេថា៖«អស់លោកពុំយល់អ្វីសោះ! ៥០តើអស់លោកគិតមិនឃើញទេឬថា បើមនុស្សតែម្នាក់ស្លាប់ជាប្រយោជន៍ដល់ប្រជារាស្ត្រនោះ ប្រសើរជាងទុកឲ្យជាតិទាំងមូលត្រូវវិនាស!»។ ៥១លោកមានប្រសាសន៍ដូច្នេះមិនមែនផុសចេញពីគំនិតខ្លួនឯងផ្ទាល់ឡើយ គឺក្នុងឋានៈជាមហាបូជាចារ្យនៅឆ្នាំនោះ លោកបានទាយថាព្រះយេស៊ូត្រូវសោយទិវង្គត ដើម្បីជាប្រយោជន៍ដល់ជនជាតិយូដា ៥២មិនគ្រាន់តែជាប្រយោជន៍ដល់សាសន៍នេះប៉ុណ្ណោះទេ គឺដើម្បីឲ្យ

កូនចៅរបស់ព្រះជាម្ចាស់ ដែលបែកខ្ញែកគ្នា មករួមរួមជាប្រជាជនតែមួយ។ [៥៣]តាំងពីថ្ងៃនោះមក ពួកនាយកបូជាចារ្យ និងពួកខាងគណៈផារីស៊ី បានសម្រេចធ្វើគុតព្រះយេស៊ូ។ [៥៤]ហេតុដូច្នេះហើយបានជាព្រះអង្គមិនយាងទៅមក ដោយចេញមុខឲ្យជនជាតិយូដា ឃើញទៀតឡើយ គឺព្រះអង្គចាកចេញពីទីនោះ ឆ្ពោះទៅតំបន់ជិតវាលរហោស្ថាន ត្រង់ភូមិមួយឈ្មោះអេប្រាអ៊ីម ហើយទ្រង់ស្នាក់នៅក្នុងភូមិនោះជាមួយសាវ័ក។ [៥៥]ពេលនោះ ជិតដល់ថ្ងៃបុណ្យចម្លងរបស់ជនជាតិយូដាហើយ។ អ្នកស្រុកជាច្រើននាំគ្នាឡើងទៅក្រុងយេរូសាឡឹមមុនថ្ងៃបុណ្យ ដើម្បីធ្វើពិធីជម្រះកាយឲ្យបានបរិសុទ្ធ។ [៥៦]គេរកព្រះយេស៊ូ ហើយនិយាយគ្នាទៅវិញទៅមក ក្នុងព្រះវិហារថា អ្នកគិតដូចម្ដេច? លោកមិនហ៊ានចូលរួមក្នុងពិធីបុណ្យទេមើលទៅ។ [៥៧]ពួកនាយកបូជាចារ្យ និងពួកខាងគណៈផារីស៊ីបានចេញបញ្ជាថា ដឹងព្រះអង្គគល់នៅឯណាត្រូវប្រាប់ពួកគេដើម្បីឲ្យគេចាប់ព្រះអង្គ។

ក.តាមគោលគំនិតនិងទស្សនៈរបស់ជនជាតិក្រិកនៅសម័យនោះ ពាក្យ«ព្រះបន្ទូល»(ឡូហ្គូស)សំដៅទៅលើគោលការណ៍ឬធម្មវិន័យដែលទ្រទ្រង់ពិភពលោកទាំងមូល។លោកយ៉ូហានប្រើពាក្យព្រះបន្ទូលនេះសំដៅទៅលើព្រះបុត្រារបស់ព្រះជាម្ចាស់។ព្រះយេស៊ូពិតជា«ព្រះបន្ទូល»ព្រោះព្រះអង្គជាប្រភពនៃអ្វីៗទាំងអស់ហើយព្រះអង្គនាំយើងឲ្យស្គាល់ព្រះបិតា។•ខ.«បែរទៅរក»:យើងអាចបកប្រែថា«គង់នៅជាមួយ»ក៏បាន។ ពាក្យនេះសំដៅទៅលើទំនាក់ទំនងដ៏ជិតស្និទ្ធរវាងព្រះបិតានិងព្រះបុត្រា។•គ. ឬ«សេចក្ដីងងឹតពុំបានយល់ពន្លឺទេ»។•ឃ. ឬមនុស្សលោក។•ង. ពាក្យដើម«តាំងព្រះពន្លា»។

ច. ឃ្លាដើម«ព្រះបុត្រាស្ថិតនៅក្នុងព្រះឱរារបស់ព្រះបិតា»។•ឆ. ម៉ាឡាគី៣.២៣។•ជ. «ព្យាការីដែលយើងទន្ទឹងរង់ចាំ»នេះសំដៅទៅលើព្រះគ្រីស្ដដែលជនជាតិអ៊ីស្រាអែលរង់ចាំស្របតាមពាក្យដែលលោកម៉ូសេបានថ្លែងទុកក្នុងកណ្ឌគម្ពីរទុតិយកថា១៨.១៥។•ឈ. អេសាយ៤០.៣។

ញ. ក្នុងឯកសារភាសាក្រិកខ្លះប្រើ«យ៉ូណាស»។

ដ. ឯកសារខ្លះមានពាក្យបន្ថែមថា«អំណើះតទៅ»។•ឋ.ពាក្យដើម: «អ្នកស្រីអើយ»។•ឌ. ឃ្លាដើម: «តើមានអ្វីរវាងខ្ញុំនិងអ្នក(ម្ដាយ)?»។

ឍ. ទំនុកតម្កើង៦៩. ១០។•ណ. ពាក្យកើតជាថ្មីនេះមានន័យម៉្យាងទៀតថា កើតពីស្ថានលើ ពោលគឺកើតពីព្រះជាម្ចាស់។•ត.ឃ្លាដើម«ជាព្រះវិញ្ញាណ» មានន័យថាគេមានព្រះជន្មរបស់ព្រះជាម្ចាស់នៅក្នុងខ្លួន។

ថ ក្នុងភាសាដើមពាក្យ«ខ្យល់»និងពាក្យ«វិញ្ញាណ»ជាពាក្យតែមួយ។

ទ. ឯកសារខ្លះមានបន្ថែមថា«បុត្រមនុស្សដែលគង់នៅស្ថានបរមសុខ»។•ធ. «លើកឡើង»មានន័យពីរយ៉ាងមួយចង់និយាយអំពីគេឆ្កាងព្រះយេស៊ូនិង មួយទៀតអំពីព្រះយេស៊ូទទួលសិរីរុងរឿង។ លោកម៉ូសេបានលើកពស់ឡើង(ជនគណនា២១.៨-៩)។•ន. ឯកសារខ្លះមានឃ្លាបន្ថែមថា«ប៉មិនត្រូវវិនាសឡើយ តែមានជីវិតអស់កល្បជានិច្ច»។

ប. ឬ«ទឹករស់»។•ផ. «ខ្ញុំនេះហើយ» ចង់សំដៅទៅលើព្រះនាមរបស់ព្រះជាម្ចាស់ដែលទ្រង់មានព្រះបន្ទូលប្រាប់លោកម៉ូសេ នៅគម្ពីរសេរីភាព(និក្ខមនំ) ៣.១៤។

ធ. សូមអានសេចក្ដីពន្យល់នៅយ៉ូហាន១.២១,២៤។•ន.ឬ«ខ្ញុំនេះហើយ»សំដៅទៅលើព្រះនាមព្រះជាម្ចាស់ដែលព្រះអង្គមានព្រះបន្ទូលប្រាប់លោកម៉ូសេក្នុងគម្ពីរសេរីភាព(និក្ខមនំ)៣..១៤។

ប.ទំនុកតម្កើង៧៨.២៤; សេរីភាព(និក្ខមនំ) ១៦.៤,១៣-១៥,៣១។• ផ. ពាក្យដើម«នំបុ័ង»។

ព. អេសាយ ៥៤. ១១ • ភ. ពាក្យដើម «សាច់ខ្ញុំ»។

ម. ពាក្យដើម«សាច់គ្មានប្រយោជន៍អ្វីឡើយ»។•យ.ឯកសារដើមខ្លះមានសរសេរថា«ព្រះអង្គជាព្រះគ្រីស្តជាព្រះដ៏វិសុទ្ធរបស់ព្រះជាម្ចាស់»។

រ. ក្នុងភាសាដើម ពាក្យ «កិត្តិយស» និង ពាក្យ «សិរីរុងរឿង» ជាពាក្យតែមួយ។

ល. ឬទទួលសិរីរុងរឿង។•វ.សូមអានសេចក្តីពន្យល់នៅយ៉ូហាន ១.២១,២៥។•ស.២សាមូអែល ៧.១២មីកា៥.១-២។

ហ.ឯកសារដើមខ្លះមានបន្ថែមថា:"ដោយសតិសម្បជញ្ញៈចោទប្រកាន់ខ្លួនគេក៏នាំគ្នាដកខ្លួនចយប៉"។

ឡ.ឬ«សត្តីភាពនោះពិត»។•អ.ពាក្យដើម «ក្នុងបាបរបស់ខ្លួន» មានន័យថា «មិនអាចរួចពីបាប» ព្រោះមិនព្រមជឿលើព្រះយេស៊ូ។ • ក. «ឋានៈរបស់ខ្ញុំ»ភាសាដើមសរសេរថា:«ខ្ញុំនេះហើយគឺជាខ្ញុំ»ឬ«ខ្ញុំស្ថិតនៅ»គឺជាព្រះនាមរបស់ព្រះជាម្ចាស់ដែលព្រះអង្គមានព្រះបន្ទូលប្រាប់លោកម៉ូសេក្នុង សេរីភាព(និក្ខមនំ) ៣.១៤។

ខ.ចង់និយាយអំពីព្រះយេស៊ូត្រូវគេឆ្កាង។ • ខខ. សូមអានសេចក្តីពន្យល់នៅខ២៤។

គ. ពាក្យ«ខ្ញុំមានជីវិត»នេះក៏ដូចនៅខ២៤និងខ២៨ដែរពាក្យដើមសរសេរថា«ខ្ញុំនេះគឺជាខ្ញុំ»ឬ«ខ្ញុំស្ថិតនៅ»ជាព្រះនាមរបស់ព្រះជាម្ចាស់ដែលព្រះអង្គមានព្រះបន្ទូលប្រាប់លោកម៉ូសេក្នុងគម្ពីរសេរីភាព(និក្ខមនំ)៣.១៤។

ឃ. «ស៊ីឡោម»ជាប្រភពទឹក នៅខាងត្បូងក្រុងយេរូសាឡឹម។

ង. យើងអាចបកប្រែថា«វាលស្មៅ»ក៏បាន។ពាក្យនេះសំដៅទៅលើព្រះបន្ទូលដែលប្រៀបបីដូចជាចំណីអាហាររបស់អ្នកជឿ។

ច. ទំនុកតម្កើង ៨២.៦។

ឆ.សូមអាន យ៉ូហាន ១២.១-៨; ម៉ាកុស១៤.៣-៩។

ជ. ឃ្លាដើម «ខ្ញុំជាការរស់ឡើងវិញ និង ជាជីវិត។

ឈ. យើងអាចបកប្រែម៉្យាងទៀតថា «ព្រះអង្គមានព្រះហឫទ័យគ្នាន់ខ្នាញ់» ឬ «ទ្រង់ព្រះពិរោធ»។ • ញ.ពាក្យដើម«ទីកន្លែង»: សម្រាប់ជនជាតិយូដា ពាក្យនេះចង់សំដៅទៅលើក្រុងយេរូសាឡឹម ហើយជាពិសេសចង់សំដៅទៅលើព្រះវិហារ។